សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Hotline news: 978-942-1641

ទទួលផ្ញើ លុយ, ឥវ៉ាន់ និង ឯកសារ ទៅស្រុកខ្មែរ និងផ្ញើមក USA វិញ ។ សូមទំនាក់ទំនង:
7 Video
(978) 710-6356
Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851

បទវិភាគ

## សម រង្ស៊ី ថា សកម្មជនជាប់ទោស ដោយសាររឿងយួន



ពិន សំខុន

**ដោយ ពិន សំខុន**

តើប្រយោគ សម រង្ស៊ី នេះបានន័យយ៉ាងដូចម្ដេច? ទី១ បើយោងតាមទោសប្រសិនបើមានកំហុសមែន ក៏មិនមែនជាសកម្មភាពឧក្រិដ្ឋដែរ ដូច្នេះទោសក៏មិនមែនខ្ពស់រហូតដល់ជាប់គុកពី៧ដល់២០ឆ្នាំដែរ ទី២ មានចំណងយ៉ាងជាក់ស្ដែងថា ហ៊ុន សែន មានក្រញាំដៃលើតុលាការខ្មែរ ដូច្នេះទី៣ ការដាក់ទោសដ៏ធ្ងន់នេះ គឺជាចំណុចដ៏រសើបរបស់ ហ៊ុន សែន ដែលត្រូវតថ្លៃដោយចង់បានអ្វីមួយក្នុងតម្លៃខ្ពស់ពីគណបក្សសង្គ្រោះជាតិ ។

តើអ្វីខ្លះទៅដែលថា មានតម្លៃខ្ពស់បំផុតនាពេលនេះសម្រាប់ ហ៊ុន សែន? យោងទៅតាមព្រឹត្តិការណ៍ដែលកំពុងតែកើតមាន គឺគាត់ពង្រឹងច្បាប់ដែលអាចបំបិតមាត់សមាគម ។ សង្គមស៊ីវិល គាត់នឹងពង្រឹងច្បាប់កុំឱ្យសហជីពអាចមានមនោសញ្ចេតនាទៅលើគណបក្សប្រឆាំងបានគាត់ពង្រឹងយោធាឱ្យបំរើគាត់ គាត់ជួយបង្កើតគណបក្សដែលប្រឆាំងនឹងគណបក្សប្រឆាំងបាន៣ ឬ៤រួចហើយ ដើម្បីឱ្យទៅបំបែកសន្លឹកឆ្នោតគណបក្សសង្គ្រោះជាតិ ។

បើតាមព្រឹត្តិការណ៍ដែលកំពុងបង្កើតនេះ បង្ហាញថា ហ៊ុន សែន មិនមានបំណងណាមួយថា នឹងចេញពីអំណាចនោះទេ គឺជាការប្រើអំណាចផ្ដាច់ការដោយប្រើម៉ាស៊ីនរដ្ឋជាឈ្នាន់ ដើម្បីឱ្យទៅដល់របបផ្ដាច់ការគ្រួសារនិយមបែប គីម អ៊ីលស៊ុង នៃប្រទេសកូរ៉េខាងជើង ។ អំណាចផ្ដាច់ការនេះ អាចរក្សាបានក៏ដោយសារអំពើអយុត្តិធម៌ពុករលួយ

**តទៅទំព័រទី ២៥**

# ពិធីបង្ហាញម៉ូតដ៏គួរឱ្យចងចាំរបស់សមាគមខ្មែរ

## CMAA host a memorable fashion show



1-Shala Murray 2-Dacey Zouzas 3-Savda Keo 4- Yun-Ju Choi 5- Amy Pessia 6-Rita Mercier 7-Andrew Jacobson 8-Bopha Malone 9-Vanna Howard -10Alethia Chalevphng 11-Michael Conway 12-George Nugent 13-Rodney M.Elliott 14-Danny Rourke 15-Soeun Sok 16-Soben Buth 17-Jim Geraghty

**ដោយ ពិន សំខុន**

សំលៀកបំពាក់គ្រឿងខ្មែរច្រើនឈុតបានត្រូវបំពាក់ នាឱកាសពិធីបង្ហាញម៉ូតសំលៀកបំពាក់ដ៏ត្រចះត្រចង់មួយដឹកនាំដោយនាង វី គង់ រៀបចំដោយសមាគមខ្មែរ កាលពីថ្ងៃទី៣១ កក្កដា ឆ្នាំ២០១៥ នៅភោជនីយដ្ឋាន លីនស្ទីនៃក្រុងជ្រៃខិត រដ្ឋម៉ាសាឈូសិត។ ភាពដ៏គួរឱ្យភ្ញាក់ផ្អើលនោះ គឺមន្ត្រីសំខាន់៧នាក្រុងឡូវែលបានក្លាយទៅជា "ថបម៉ដិល"

**តទៅទំព័រទី ០៦**

ការិយាល័យ មេធាវី ថំមាស ស្ទាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration • អន្តោប្រវេសន៍
• Auto Crash • គ្រោះថ្នាក់រថយន្ត
• Divorce • លែងលះប្ដីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថានសេនជូរី : យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!



• ផ្ដល់សេវាដល់ទីលំនៅ
• ខ្ចប់ឱសថតាមបំណង
• ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

REMEDIUM PHARMACY
ឱសថស្ថានរ៉េមីឌ្យម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ
• ការលាយផ្សំឱសថ • បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
• ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Bliterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជា
ឱសថ
ស្ថានមួយ
ដែលអាចផ្តល់
ភាពជឿជាក់
ដល់គ្រួសារ
លោកអ្នក




យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ែរ, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។

ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

លេខទូរស័ព្ទ 978-455-6554

លេខហ្វាក់ 978-455-9476

937 Gorham St Lowell, MA, 01852

# About the Town

by Deb Belanger

AW summer! So man choices to sit back and relax with the family. The Greater Merrimack Valley Convention & Visitors Bureau invites locals and visitors to immerse themselves in the region where history, culture and fun unite and enjoy activities and live music that are FREE throughout the summer. Come join in on the fun!

What better way to enjoy a summer day with your children without spending a dime? Come down to Boarding House Park in Lowell, MA and watch a show/performance, TOTALLY FREE, that you and your children will love, followed by a free Trolley Ride through the city of Lowell. All shows are free and each will include:

- 10:00am Make-and-take-art
- Natural and organic snacks
- 11:00am Performance
- Noon National Trolley Park rides

August events are as follows:

- Airborne Comedians- Wednesday August 12, 2015 @ 11:00am
- Josh & The Jamtones- Thursday August 13, 2015 @ 11:00am

Looking to spend a Friday night with the whole family at a concert that everyone can enjoy? Look no further! Lexington Summer Concert Series takes place on Friday nights and the shows are TOTALLY FREE! The shows take place on the lawn at the Lexington Visitors Center from 6:30pm-dusk throughout the entire summer. Bring the family, a blanket,




and your best dancing moves! The August lineup is as follows:

- Jumpin' Juba (Boogie Woogie& NOLA Roots)- Friday August 14, 2015
- Soft Touch Dance Band (Big Band Brass)- August 21, 2015
- Boston Blackthorne (Traditional Irish Music)- August 28, 2015

Come join us at Heritage Farm Ice Cream & Restaurant every Monday night for a free outdoor concert. The concerts take place at the **Continued to Page 14**

# ការិយាល័យទេសចរ "មីរីម៉ាកវ៉ាឡេ"

សូមអញ្ជើញអ្នកនៅក្នុងឬក្រៅក្រុងមកទស្សនាកំសាន្តក្រុងប្រកបដោយប្រវត្តិសាស្ត្រ វប្បធម៌ នឹងភាពរីករាយជាមួយនឹងសកម្មភាពភ្លេងនឹងចម្រៀងដែលមិនចាំបាច់ចំណាយលុយ នាពេញរដូវក្តៅ។

សូមនាំក្មេងៗមកលេងដោយគ្មានចំណាយតែ១សេនក៏គ្មានមាននៅកន្លែង Boarding House Park in Lowell, MA មើលល្ខោន កំប្លែង ចម្រៀង នឹងជិះរថភ្លើងត្រឡេ ដោយគ្មានចំណាយអ្វីទាំងអស់។

- 10:00am Make-and-take-art
- Natural and organic snacks
- 11:00am Performance
- Noon National Trolley Park rides

ព្រឹត្តកាណ៏កំសាន្តខែសីហាៀងុសត វេនេតស ារេ ាស ថៀលល្បឿស៊

- Airborne Comedians- Wednesday August 12, 2015 @ 11:00am
- Josh & The Jamtones- Thursday August 13, 2015 @ 11:00am

រកកំសាន្តជាមួយគ្រួសារសម្រាប់រាត្រីថ្ងៃសុក្រ? មានក្រុមតន្ត្រីរដូវក្តៅនៅ "ឡេកស៊ីនតុន" នឹងសិល្បផ្សេងៗនៅរាត្រីថ្ងៃសុក្រ FREE!

ក្រុមដែលមកសម្តែងបន្តរបន្ទាប់គ្នា នាខែសីហានៅក្រសួងទេសចរ "ឡេកស៊ីនតុន" សូមនាំគ្រួសារមកមើលកំសាន្តទាំងអស់គ្នា

- Jumpin' Juba (Boogie Woogie& NOLA Roots)- Friday August 14, 2015
- Soft Touch Dance Band (Big Band Brass)- August 21, 2015
- Boston Blackthorne (Traditional Irish Music)- August 28, 2015 **តទៅទំព័រទី ២៤**

## Lowell Election Commission Reschedules Preliminary Election

LOWELL, MA -- The Election Commission has unanimously voted to reschedule the City Preliminary from Tuesday, September 22, 2015 to Tuesday, September 29, 2015 to avoid conflict with Yom Kippur. Lowell joins other cities in voting to change the preliminary date. The voter registration deadline will be Wednesday, September 9, 2015 and the deadline to apply for absentee ballots will be Monday, September 28, 2015 at 12 PM.

## ថ្ងៃបោះឆ្នោតជុំទី១បានត្រូវលើកពេល

**ឡូវែល:** គណកម្មការបោះឆ្នោតនៅឡូវែលបានសម្រេចជាឯកច្ឆន្ទលើកថ្ងៃបោះឆ្នោតជុំទី១ ពីថ្ងៃ២២កញ្ញា ២០១៥ ទៅ ២៩កញ្ញា ២០១៥វិញ ដើម្បីកុំឱ្យជាន់បុណ្យ "យុមគីពួ" ឡូវែលនឹងក្រុងឯទៀតៗក៏ធ្វើដូចគ្នាដែរ។ ថ្ងៃបញ្ចប់នៃការចុះឈ្មោះបោះឆ្នោតនឹងត្រូវជាថ្ងៃ ៩កញ្ញា២០១៥ រីឯថ្ងៃបញ្ចប់នៃការចុះឈ្មោះសុំបោះឆ្នោត "អវត្តមាន" ក៏លើកទៅថ្ងៃចន្ទ




២៨កញ្ញា២០១៥ម៉ោង១២ថ្ងៃត្រង់៕

**ប្រែសម្រួលដោយខ្មែរផុសស.រ.អា**






"អត្ថបទទស្សនៈ ថវិការគ្រួសារជាអ្វី?"

# និយាយពីក្រ និងមាន

## ភាគ៣ - ការពារសេដ្ឋកិច្ចគ្រួសារ

**ដោយ ពិន សំខុន**



ពិន សំខុន

ខុសពីទម្លាប់ស្រុកខ្មែរយើងមុនពេលចេញមករស់នៅអាមេរិកនេះ ទៅសុំការងារគេធ្វើទាំងធំទាំងតូច គឺមិនខុសពីទាសករទេ បានប្រាក់ខែតិចហើយធ្វើតាមតែគេថា គេកាត់កងអីក៏ក៏តាមតែគេថាដែរ ដូច្នេះមិនអាចគ្រោងអ្វីឱ្យទៅជាអ្នកមានបានទេ ទោះជាខំសន្សំយូយ៉ាងណាក៏ដោយ ។

ឥឡូវយើងរៀនគិតសារជាថ្មី ពីព្រោះការងារយើងធានាដោយច្បាប់ប្រាក់ចំណូលក្នុងផ្ទះ ក៏ត្រូវតែយើងដឹងហើយមានការយល់ព្រមជាមុន។ កាងារសុទ្ធតែមានចុះកិច្ចសន្យាកិច្ចសន្យាត្រូវតែមានការយល់ព្រមទាំងភាគីម្ចាស់ហាងនឹងអ្នកធ្វើការ។ ការងារដែលទៅធ្វើជាការងារដែលយើងចូលចិត្តស្របទៅតាមថ្លៃឈ្នួល ហើយនឹងពេលម៉ោងដែលយើងបំរើការងារ:

**-លុយពេល=**តម្លៃនៃប្រាក់ឈ្នួល... ដែលក្នុងនោះត្រូវដកអតិផរណានឹងពន្ធ... ទើបនៅសល់ប្រាក់ចំណូល គឺនៅលើប្រាក់ចំណូលនោះហើយដែលយើងយកមកចាយវាយជាចាំបាច់ដ៏ច្រើនមុខ... សល់ ឬក៏ជំពាក់ ។

**តើសន្សំនៅពេលណា ?**

អ្នកឯកទេសខាងហិរញ្ញវត្ថុនិយាយថា"កុំសន្សំអ្វីដែលសល់ពីចាយ គឺចាយអ្វីដែលសល់ពីសន្សំ" បានន័យថា ការសន្សំគឺជាវិន័យ ទោះជាក្រ ឬមានមានការងារ ឬអត់ត្រូវតែសន្សំជាទៀងទាត់យ៉ាងព្យាយាម ទោះជាគ្មានលុយសម្រាប់ចាយក៏ដោយ ។



source: Rich Dad Poor Dad



**គោលការណ៍សន្សំតក់ៗ**

ការសន្សំនេះ មិនទាក់ទងទៅលើចំណោះរបស់ម្តាយឪពុក ឬត្រូវតែមានប្រាក់ចំណូលច្រើន ឬការងារជាកម្មករ ឬមន្ត្រីអ្វីនោះទេ ទាក់ទងតែមួយគត់ គឺការប្តេជ្ញាចិត្តគោរពពាក្យសន្យារបស់ខ្លួនឯងតែប៉ុណ្ណោះ ។

**ទ្រឹស្តីទី១-** កាលពីនៅស្រុកខ្មែរគ្រួសារចៅចិនជាច្រើននិយាយប្រាប់ខ្ញុំថា "មិនត្រូវចាយប្រាក់ដែលទទួលបានម្តងៗឱ្យអស់រលីងទាំងអស់នោះទេ" បានន័យថា បើអ្នកទទួលលុយថ្ងៃនេះ ជារបស់អ្នក១០រៀល ត្រូវសន្សំទុកឱ្យបានយ៉ាងហោចណាស់ក៏១រៀលដែរ ។ លុយ១រៀលនោះ មានតម្លៃណាស់ ព្រោះជាលុយ"សន្យា"ត្រូវរក្សាឱ្យបានយូរនៅកន្លែងសម្ងាត់ណាមួយ...ស្អែកឡើងយើងទទួលបាន៥រៀលជារបស់យើងទៀត ទោះជាក្នុងករណីណាក៏ដោយត្រូវរក្សា១រៀលចុងក្រោយក៏មិនចាយវាយវាជាដាច់ខាត ហើយយក១រៀលនេះ ទៅទុកបូកជាមួយនឹង១រៀលមុនជាលុយសម្ងាត់ឬលុយសន្សំវាទៅជា២រៀល ។ បើមានលុយចូលជារាល់ថ្ងៃ១ឆ្នាំក្រោយមកលុយសម្ងាត់នោះនឹងក្លាយទៅជា៣៦៥រៀល ហើយគ្រួសារចៅចិន គេផ្តើមបង្ហាត់កូនគេតាំងពីអាយុ៥ឆ្នាំនៅពេលគេបង្ហាត់កូនគេឱ្យស្គាល់លុយចាយលុយដោយខ្លួនឯងឱ្យលុយទៅទិញនំឱ្យលុយទៅសាលារៀនហាត់ "អាប់លុយ"ពេលលក់របស់អ្វីមួយបានហាត់សងប្រាក់ជំពាក់...ហើយចិនគេប្រកាន់ខ្លួនណាស់ "តែជំពាក់ត្រូវតែសង" បើមិនដូច្នោះទេ នឹងខូចឈ្មោះថាជាអ្នកមិនរក្សាពាក្យសន្យាមិនអាចរកស៊ីជាមួយគេឯងទៅថ្ងៃក្រោយបានទេ ។

សូមពិចារណាទៅមើល! ២០ឆ្នាំក្រោយមកការសន្សំលុយសម្ងាត់នៅនឹងក្លាយទៅយ៉ាងណា

**តទៅទំព័រទី ២០**









# More benefits. $0 cost.

If you are 65 or older and qualify for MassHealth Standard, our plan could get you more benefits than Original Medicare.

With **UnitedHealthcare® Senior Care Options (HMO SNP)**, your doctor, hospital and prescription drug coverage are all under one convenient card.

Plus, you'll get extra benefits — at no cost to you. These extra benefits include:

- **$0 co-pay** for dental cleanings, fillings, dentures and more.
- **$0 co-pay** for all covered medications.
- **$0 co-pay** for eyewear.
- **$0 co-pay** for rides to doctor appointments.





Call **1-781-888-7779, TTY 711,** and one of our local, licensed agents can help you find out if you could get more benefits at no cost to you.

UnitedHealthcare®
Community Plan

UnitedHealthcare SCO is a Coordinated Care plan with a Medicare contract and a contract with the Commonwealth of Massachusetts Medicaid program. Enrollment in the plan depends on the plan's contract renewal with Medicare. This plan is a voluntary program that is available to anyone 65 and older who qualifies for MassHealth Standard and Original Medicare. If you have MassHealth Standard, but you do not qualify for Original Medicare, you may still be eligible to enroll in our MassHealth Senior Care Option plan and receive all of your MassHealth benefits through our SCO program. The benefit information provided is a brief summary, not a complete description of benefits. For more information contact the plan. Limitations, co-payments and restrictions may apply. Benefits, formulary, pharmacy network, provider network, premium and/or co-payments/co-insurance may change on January 1 of each year. Premiums, co-payments, co-insurance and deductibles may vary based on the level of Extra Help you receive. Please contact the plan for further details. Enrollees have no out of pocket costs.

H2226_150326_160615 Accepted
UHCSCO_150326_160615

តមកទំព័រទី ០១

# ពិធីបង្ហាញម៉ូដដ៏គួរឱ្យចងចាំ....

នៃសំលៀកបំពាក់គ្រឿងខ្មែរដែលមានប្រវត្តិពាន់ឆ្នាំធ្វើឱ្យពិធីនារាត្រីនោះក្លាយជារាត្រីសមោសរដ៏អស្ចារ្យមួយ ។

មន្ត្រីជាន់ខ្ពស់តិចនៅឡើយ ដែលបានផ្តល់កិត្តិយសដល់សំលៀកបំពាក់ប្រវត្តិសាស្ត្រខ្មែរនៅសហរដ្ឋអាមេរិកឱ្យបានប្រសើរដូចនៅក្រុងឡូវែលនេះណាស់ ។ រំលឹកពីប្រវត្តិនោះក្រណាត់សំពត់ល្អៗនឹងគ្រឿងអលង្ការបានទៅដល់ជាលើកដំបូងនៅស្រុកខ្មែរនាសតវត្សទី១នៃគ្រឹស្តសករាជ្យនៅពេលដែលឈ្មួញឥណ្ឌាបានជិះសំពៅមកដល់ជ្រោយសុវណ្ណភូមិរៀបអភិសេកជាមួយព្រះនាងសោមាបង្កើតបានជារាជ្យវង្សកោឌិណ្យបានធ្វើឱ្យខ្មែរមានសំពត់អាវប្រណិតជាលើកដំបូងបង្អស់... ហើយក្រណាត់សំពត់នឹងអលង្ការទាំងនោះ បន្តដំណើរវិវត្តន៏របស់ខ្លួនតាំងពីពេលនោះមកឆ្លងកាត់សម័យអង្គរនៃព្រះរាជវង្សវ៌្មនក៏បានចារុឆ្លាក់រូបសំពត់អាវទាំងអម្បាមាណនៅលើថ្មនៃប្រាង្គប្រាសាទអង្គរ កាលពី១៥០០ឆ្នាំមុន រហូតមកដល់សព្វថ្ងៃមានអាយុ២០០០ឆ្នាំហើយ ។

ដល់ថាលោកអភិបាលក្រុង រ៉តនី អេលិយ៉ុត ឬក៏គណកម្មាភិបាលក្រុងរីដា មើស៊ីយេ ឬក៏ ដាន់រូក ឬក៏ ម៉ាយខិល ខនវ៉េយ នឹងអ្នកឯទៀត









រាត្រីនោះ ពោរពេញទៅដោយការសើចហ៊ោកញ្ជ្រៀវកោតសសើរនៅពេលឃើញតួសម្តែងម៉ូដមិនមែនខ្មែរមានសំពត់អាវគ្រឿងនឹងអលង្ការខ្មែរនៅលើខ្លួន ជាពិសេសមិនមាននរណាស្មានសម្តែងនិងស្លៀកពាក់បានសមយ៉ាង ដូច្នេះសោះ ហើយប្រើអកប្បកិរិយាជាខ្មែរទៀតផង ដោយដំណើរដោយរបៀបសំពះដោយស្នាមញញឹមជាប់នឹងបបូរមាត់... ដើរជាគូរៗជាមួយនឹងតួសម្តែងជាខ្មែរ ដែលជាអ្នកមានកិត្តិយសដូចគ្នារូបរាងក៏សមសង្ហាដូចគ្នា ដូចជាអ្នកស្រី វណ្ណាហូវើដ ជាដើមធ្វើឱ្យទស្សនិកជនមិនអាចមិនសសើរមិនបានឡើយ ។

ភ្ញៀវបានទស្សនាការដង្ហែក្បួនជាខ្មែរតែក៏មានដង្ហែក្បួនផ្សេងទៀតដែរ ជាមួយសំលៀកបំពាក់ចេញកំសាន្តនារាត្រីថ្ងៃសៅរ៍ធ្វើឱ្យតួសម្តែង

តទៅទំព័រទី ០៩



# REMEDIUM PHARMACY

2 VINAL Square
N. Chelmsford, MA 01863

Phone: (978) 251-7070

## FREE Daily Home Delivery



**Blisterpack Packaging**

**Friendly Consultations**

**Compounded Medications**

**Easy Transfers**

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និងការពិសោធន៍ក្នុងការបំរើលោកអ្នក។




ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវៈ

**ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ**

**ដាកៅឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល**

**ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល**

**មានផ្តល់ជូនម្សៅថ្នាំលាយ**

**ភាពងាយស្រួលក្នុងការផ្ទេរចេញចូល**



Cristina គ្រីស្ទីណាៈ
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



Kelly ខែលលីៈ
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្រ្តរដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់ក៏ជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



Pahim លោកប៉ាហ៊ីមៈ
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តាព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឱ្យកាន់តែខ្លាំងខ្លាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



Daniela ដានីញែលឡាៈ
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



Dary ដារីៈ
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបប្រាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



Kassandraកាសាន់ដ្រាៈ
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្បានិសសដែលរស់កក្នុងងក្រុងឡឡូវែលលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។

# បក្សប្រជាជនកម្ពុជាចាប់កំញើញបក្សសង្គ្រោះជាតិ


លឹម គិមយ៉ា

**តពីលេខមុន**

សម្តេចប្រធានមិនគោរពរដ្ឋធម្មនុញ្ញចេញទៅប្រហែលសភាពការណ៍ធូរស្រាល។ ឱ្យគាត់រៀនសូត្រថែមតិចទៀត។ ការដែលលោក ឈាង វុន និយាយយ៉ាងនេះ ពីព្រោះការដែលសម្តេចប្រធានសភាមិនបានផ្ញើសំបុត្រទៅនោះ គឺជាការរំលោភសិទ្ធិលើសមាជិកតំណាងរាស្ត្រ និងមាត្រា៩៦ នេះមែន ពីព្រោះលោក ឈាង វុន ចង់សំរួល បើមិនយ៉ាងនេះទេ គាត់មិននិយាយយ៉ាងស្រួលយ៉ាងនេះ បើគេស្គាល់សារជាតិរបស់គាត់។

ដោយលោក អ៊ុំ សំអាន មិនព្រមតាមសំណើរនេះ នៅព្រឹកថ្ងៃទី២៤ ខែកក្កដាគណៈ-កម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាដែលមានសមាជិកមកពីគណបក្សប្រជាជនកម្ពុជា៧នាក់ និងសមាជិកមកពីគណបក្សសង្គ្រោះជាតិមានតែ៦កោះប្រជុំកាត់ទោសលោក អ៊ុំ សំអាន ដោយគ្មានវត្តមានរបស់លោក ។ ការដែលគណៈកម្មាធិការអចិន្ត្រៃយ៍សំរេចដោយយកលេសថា ខុសពីបទបញ្ជាផ្ទៃក្នុងរបស់សភា ហើយពិន័យទៅតាមប្រការ៨១ គឺទី១ កាត់ប្រាក់ខែ៥០ភាគរយ រយៈពេល២ខែ ទី២ផ្សព្វផ្សាយនូវទោសកំហុសហើយបិទនៅគ្រប់ឃុំក្នុងមណ្ឌលសៀមរាប និង ទី៣ហាមមិនឱ្យចូលរួមប្រជុំសភាចំនួន១៥លើក។

ការដែលសំរេចនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាពីមុនៗឃើញមានភាពមិនប្រក្រតីជាច្រើនដងទៅហើយ ដោយអះអាងទាំងកំរោលថា ស្របតាមច្បាប់ ដូចជាដេញសមាជិកសភា២៩នាក់របស់គណបក្សសមរង្ស៊ី និងសិទ្ធិមនុស្សកាលពីខែមេសា២០១៣ លោកឈាងវុនដដែលនេះបានអះអាងថាត្រូវ និងស្របច្បាប់ដល់គេសួរតើមាត្រាណាមួយលោកឈាងវុនអត់ឆ្លើយ និងនិយាយទេ សំរេចសំរួចសុខចិត្តបើកប្រាក់ខែដល់សមាជិកសភាដែលដេញនោះ នេះគឺបានសេចក្តីថា ការសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភានៅពេលនោះគឺខុស និងរំលោភលើច្បាប់ ។ ការសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាស្តីពីលោក អ៊ុំ សំអាន នេះក៏ខុស និងរំលោភលើច្បាប់ដែរ ដែលមិនស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ១៩៩៣ និងបទបញ្ជាផ្ទៃក្នុងរបស់សភាដែរដោយពួកអស់នេះសំអាង។

នៅលើសេចក្តីសម្រេចរបស់គណៈកម្មការអចិន្ត្រៃយ៍នៃរដ្ឋសភាកាលពីព្រឹកថ្ងៃទី២៤ កក្កដានេះ ដោយមានហត្ថលេខារបស់សម្តេចប្រធានរដ្ឋសភាលោក ហេង សំរិន ក្នុងប្រការ១ ចែងទៀតថាសកម្មភាពរបស់តំណាងរាស្ត្រ អ៊ុំ សំអាន ដែលបានផ្សាយចេញតាមបណ្តាញព័ត៌មានសង្គមហ្វេសប៊ុក (Facebook) កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ក្រោយពីសម្ភាសន៏ជាមួយអ្នកសារព័ត៌មានដោយអះអាងថា "លោក ហេង សំរិន ហាក់ដូចជាមិនចង់អោយតំណាងរាស្ត្រទៅវីរវល់ជាមួយបញ្ហាព្រំដែន។ ហើយភូមិរបស់លោក ហេង សំរិន ដែលវៀតណាមយកទៅ គឺលោក ហេង សំរិន មិនហ៊ានក្អកឡើយ"។ ចាត់ទុកជាអំពើនាំឱ្យប៉ះពាល់ដល់កិត្យានុភាពរបស់រដ្ឋសភា និងជាការប្រមាថមើលងាយប្រធានរដ្ឋសភាដែលផ្ទុយពីមាត្រា៨៧នៃរដ្ឋធម្មនុញ្ញព្រមទាំងប្រការមួយចំនួនទៀតនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

បើយើងសិក្សាពីមាត្រា៨៧។ -នៃរដ្ឋធម្មនុញ្ញនោះ ដូចមានខាងក្រោមនេះ គឺគ្មានទំនាក់ទំនងអ្វីទេ នឹងការចោទប្រកាន់នេះ ។

"មាត្រា ៨៧។ -ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភាទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័តរ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈមិនអាចបំពេញមុខងារបានដោយហេតុមកពីមានជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទីឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេសអនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែងឬទទួលអនិច្ចកម្មរដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធានឬអនុប្រធានថ្មី"។

ទាក់ទងនឹងបញ្ហានេះមន្ត្រីសង្គមស៊ីវិលចាត់ទុករឿងនេះថាជាសិទ្ធិបញ្ចេញមតិ និងជាកាតព្វកិច្ចរបស់តំណាងរាស្ត្រដែលត្រូវធ្វើ។

ប្រធានអង្គការខុមហ្វ្រែល (Comfrel) លោក គល់ បញ្ញា ថ្លែងថាទាំងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាមិនមានចែងទាល់តែសោះថា ប្រធានរដ្ឋសភាត្រូវបានហាមឃាត់ដាច់ខាតមិនឱ្យរិះគន់ ឬនិយាយប៉ះពាល់មិនបាននោះទេហើយក៏មិនមែនរាល់ការរិះគន់ទាំងឡាយត្រូវតែបកស្រាយទៅជាការប្រមាថមើល

**តទៅទំព័រទី ១១**



## តមកទំព័រទី ០៦ ពិធីបង្ហាញម៉ូដដ៏គួរឱ្យចងចាំ....

ដដែលប្តូរសម្លស្សស្មើមើលមិនស្គាល់។ ភ្ញៀវម្នាក់បានកត់សំគាល់ថា រ័តនី ស្លៀកខោអាវ "ស៊្វិត"ខ្មៅមិនបានបង់កដោយកន្សែងសូត្រពណ៌ស ទេ តែជំនួសដោយក្រមាខ្មែរក្រឡាខ្មៅ។ ក្រហម មកបង់កបានធ្វើសំលៀកបំពាក់មួយគ្រឿងនោះ ក្លាយជាម៉ូដអាស៊ីទៅវិញ បើគេមិនឃើញមុខ គេនឹងថាម្នាក់នោះជាជនអាស៊ីជាប្រាកដ។ នៅ មានឈុតលំហែរកាយ នារដូវក្តៅមានខោអាវខ្លី សម្រាប់ប្រុសខាងស្រីសំពត់អាវចំរុះពណ៌ក្រណាត់ ទន់ស្តើងហើយទូលាយដែលគួរឱ្យចង់សើចជាង គេគឺ អេនឌ្រូ យ៉ាកុបសុន ស្លៀកខោខ្លី អាវខ្លី ចំហរទ្បេវ ហើយកាន់បន្ទះឈើល្បែង"ស្កេត" ចេញមកដោយសារខ្លួនមាឌតូចផង ឃើញដូចជា "កុមារស្កេតប៊ីត" មែនទែនតែម្តង។ សំលៀក បំពាក់គ្រឿងផ្តល់ដោយហាង "MITPortail" នឹងសំលៀកបំពាក់រាត្រី ឬលំហែរដោយហាង "Hunamity Boutique"នឹងហាង"Gentleman"។

ពិធីករនារាត្រីនោះ សម្តែងដោយ វីរ អ៊ុយ ជាអនុប្រធានសមាគមខ្មែរកំដររាត្រីដង្ហែរក្បួន ម៉ូដជាមួយនារីដ៏ស្រស់ប្រិមប្រិយម្នាក់ឈ្មោះ សេទ្បា មួរ៉េ ជាបវរកញ្ញា "ញូអិនក្លិន" ឆ្នាំ២០១៥។ អ្នកទាំងពីរបានណែនាំទស្សនិកជនឱ្យស្គាល់ សមាសភាពនៃសិល្បករបង្ហាញម៉ូដបង្ហាញ ភ្ញៀវបង្ហាញសមាគមដែលធ្វើឱ្យបរិយាកាស ពោរពេញដោយសំណើច ថ្វីបើម្ហូបទទួលភ្ញៀវ រាងខើចបន្តិចមែនតែគ្មាននរណារអ៊ូថា ខ្លួនហូប មិនឆ្អែតនោះទេ ពីព្រោះមានភ្ញៀវប្រមាណជិត ៣០០នាក់ ក៏គេចង់ឃើញសមាគមខ្មែរនៅ សល់ថវិកាបានច្រើនដែរ។ មានសំណាងល្អបន្តិច ដែរ ដែល"ខ្មែរផុស"បានទិញឆ្នោតវត្ថុ៥សន្លឹក ហើយត្រូវបានរង្វាន់គ្រឿងសំអាងកាយបុរស ហើយអរគុណដល់ម្ចាស់អំណោយដែលយើង មិនបានចាប់អារម្មណ៍ ហើយចាំថា ជានរណា នោះ ដូច្នេះមិនអាចឱ្យយើងបង្ហាញឈ្មោះនៅ ពេលនេះបាន។

កម្មវិធីសមាគមខ្មែរមួយនេះយើងយល់ថា បានឆ្លុះបញ្ចាំងបង្ហាញពីការវិវត្តន៏របស់សហគមន៏ ខ្មែរដែលកំពុងរលាយចូលរួមគ្នាជាមួយសហគមន៏ ឯទៀត ដែលរស់នៅជុំវិញខ្លួន ដើម្បីឱ្យក្លាយ ជា"ខ្មែរ.អាមេរិកាំង"។ គឺជាសហគមន៏ថ្មីដែល បន្តនិរន្តភាពពីសហគមន៏មុនដែលមានឈ្មោះថា "ខ្មែរភៀសខ្លួន" ជាមួយនឹងការគិតបែបថ្មីរីករាយ នឹងវប្បធម៌ថ្មីរបៀបរស់នៅបែបថ្មី ដើម្បីការ លូតលាស់ប្រសើរនៃអ្នកជំនាន់ក្រោយនៃមនុស្សដែលមានឫសគល់ជាខ្មែរ ៕








TRITON STAFFING GROUP

330 Boston Rd. Billerica, MA 01862 Phone: (978)663 2013 fax (978)663 2513

**ត្រូវការជ្រើសរើសបុគ្គលិកជាប្រញាប់**

**យើងគឺជាក្រុមហ៊ុនសេវារកអ្នកធ្វើការ**

យើងមានការងារបើកថ្មីនៅតំបន់ឡូវែល បីលរិកា នឹងនៅខាងត្បូង តំបន់ញូហាមស្ពៀ

Triton Staffing Group is a full service staffing agency located at 330 Boston Road, Billerica, MA 01862, Phone: 978-663-2013, Fax:978-663-2513
We currently have job openings in the Great Lowell, Billerica and Southern New Hampshire areas.

| **Positions Available Include :** | | **ការងារដែលមាន :** | |
|---|---|---|---|
| -Machine Operators | បញ្ជាគ្រឿងម៉ាស៊ីន | -Assemblers | រៀបគ្រឿងផ្គុំ |
| -Warehouse | ការងារក្នុងឃ្លាំងអីវ៉ាន់ | -General Labor | ការងារទូទៅ |
| -Administrative | រដ្ឋបាល | -Shipping, Receivers | ផ្ញើរអីវ៉ាន់, ទទួលអីវ៉ាន់ |
| -Technicians | បច្ចេកទេសជាង | -CNC Operators | អ្នកបញ្ជា ស៊ីអិនស៊ី |
| -Data Entry | បញ្ចូលព័ត៌មាន | -Cable Harness | តម្លើងខ្សែរអាសន្សាណ |
| -Welders | ជាងផ្សារដែក | | |

សូមអញ្ជើញមកចុះឈ្មោះ យកប្រវត្តិរូបមកផង ឬក៏ឱ្យបុគ្គលិកយើងជួយមើល ធ្វើឱ្យមួយ។
Come in and apply, please bring a resume or have one of our recruiters assist you with one.

**TRITON STAFFING GROUP**
**978-663-2013**





ឌឹ ខេមបូឌា ដេលី The Cambodia Daily
ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# សំណូកនៅអាកាសយានដ្ឋានបន្តរំខានភ្ញៀវទេសចរ

**ដោយ ហួត ចាន់ប៉ាវ និង សៃម៉ុន ហេនឌឺរសិន** | **August 5, 2015**

ប្រធានក្រុមការងារទេសចរណ៍បាននិយាយថា លោកបានប្រាប់រដ្ឋាភិបាលអំឡុងកិច្ចប្រជុំចុងក្រោយរបស់លោកក្នុងតំណែងថា ភ្ញៀវទេសចរអន្តរជាតិដែលធ្វើដំណើរមកប្រទេសកម្ពុជានៅតែត្រូវគេទារសំណូកបន្តិចបន្តួចនៅពេលចូលប្រទេសនេះ បើទោះជាមានការសន្យាកាលពីពីរបីឆ្នាំមុន ថានឹងបំបាត់លែងឱ្យមានការធ្វើដូច្នេះក៏ដោយ ។

អាកាសយានដ្ឋាននិងច្រកព្រំដែនរបស់ប្រទេសកម្ពុជាមានឈ្មោះអាក្រក់ ព្រោះមន្ត្រីដែលបានទាមទារ "លុយទឹកតែ" ពីភ្ញៀវ ។ ក្នុងឆ្នាំ ២០១៣ អ្នកកាសែតចិនម្នាក់បានសរសេរអត្ថបទរិះគន់យ៉ាងខ្លាំងក្នុងកាសែត គ្លូបល ថាមស៍ បន្ទាប់ពីក្រុមមន្ត្រីនៅឯអាកាសយានដ្ឋានអន្តរជាតិបានសុំឱ្យនាងបង់សំណូក ។

យោងតាមលោក ហូ វណ្ណី សហប្រធានជិតផុតអាណត្តិនៃក្រុមការងារវិស័យរដ្ឋាភិបាល-ឯកជនផ្នែកទេសចរណ៍បាននិយាយថា លោកបានលើកបញ្ហានេះនៅកិច្ចប្រជុំកាលពីថ្ងៃអាទិត្យដែលនៅពេលនោះ ចុងភៅធំ និងជាម្ចាស់សណ្ឋាគារលោក លូ ម៉េង ត្រូវបានតែងតាំងជាអ្នកកាន់ការជំនួសលោកបានឱ្យដឹងថា បញ្ហានេះនៅតែបន្តមាន ។

លោកបាននិយាយថា "បញ្ហានេះឱ្យនៅតែ "កើតឡើងនៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងនៅតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត និងបាវិត ហើយជនរងគ្រោះភាគច្រើនជាទេសចរចិន និងតៃវ៉ាន់" ។

លោកបានបន្ថែមថា "ប្រសិនបើការទទួល

**តទៅទំព័រទី ២៣**

# Airport Bribes Continue to Plague Visitors

**BY HUOT CHANPAV AND SIMON HENDERSON | AUGUST 5, 2015**

International visitors to Cambodia are still being asked to hand over small bribes upon entering the country, despite promises over the past few years to stamp out the practice, the head of a tourism working group said he told the government during his last meeting in the position.



Travelers exit the arrivals gate at Phnom Penh International Airport on Tuesday afternoon. (Jens Welding Ollgaard/The Cambodia Daily)

Cambodia's airports and border checkpoints are notorious for the immigration officers who demand "tea money" from visitors. In 2013, a Chinese journalist penned a scathing article in the Global Times newspaper after officials at Siem Reap International Airport asked her to pay a bribe.

But the problem persists, according to Ho Vandy, outgoing co-chair of the Government-Private Sector Working Group on Tourism, who said he raised the issue at a meeting on Sunday, during which chef and hotelier LuuMeng was named as his replacement.

"This problem [still] happens at Phnom Penh International Airport and Siem Reap International Airport, and at the Poipet and Bavet international checkpoints, and the victims are mostly Chinese and Taiwanese tourists," he said.

"If our hospitality is bad, they will remember," he added. "It affects them psychologically. In return, this affects Cambodia's tourism industry in both private and state sectors."

Lieutenant General KeoVannthan, deputy director of the Interior Ministry's immigration department, denied that his officers took bribes.

"I have never heard of this. We have put signs up at the airport [advising travelers] about tip demands," **Continued to Page 20**

ព័ត៌មានខ្លីៗ ៣

# "អេលមិនថែ្ល"នឹងបើកទ្វារថែមនុស្សចាស់

## "Element Care" will open soon in Lowell

**ឡូវែល:** ចាស់ៗនៅឡូវែលនេះមានសំណាងច្រើនដោយ"អេលមិនឃែ"ដែលធ្លាប់បំរើអ្នកស្រុក"លីន"ច្រើនឆ្នាំមកហើយ ឥឡូវមកបំរើចាស់ៗនៅឡូវែលទៀត នៅខែក្រោយនេះហើយ ។ នៅអាគារ៤ជាន់ កំពុងរៀបចំជាថ្មីស្រឡាងឡើងវិញ ស្ថិតនៅផ្លូវ Central Street នឹងបើកទ្វារទទួលថែរទាំមនុស្សចាស់ឱ្យនៅមាំមួនមានសុខភាពប្រសើរ ហើយមានសេចក្តីរីករាយក្នុងជីវិតនៃមនុស្សចាស់ក្នុងសហគមន៍បាន ។



ក្រុមជំនាញខាងវិជ្ជាពេទ្យរបស់"អេលមិនឃែ" ធ្វើការរួមដៃជាមួយមនុស្សចាស់ដែលមានអាយុពិ៥៥ឆ្នាំឡើងទៅតាមកម្មវិធីមួយមានឈ្មោះថា"ផេស Pace" ដើម្បីជួយគ្រប់គ្រងអសមត្ថភាពនៃជរាភាព ។ "ផេស"ធានាថា នឹងផ្តល់ថ្លៃថ្នាំពេទ្យថ្លៃយានដឹកនាំទៅមកថ្លៃជួបគ្រូពេទ្យ ការបំរើនៅផ្ទះ ថ្លៃពិនិត្យទូទៅថ្លៃសំណាក់នៅក្នុងពេទ្យ ហើយនឹងថ្លៃស្នាក់នៅក្នុងថែរក្សាមនុស្សជរានៅពេលណាដែលចាំបាច់ ។

ការផ្សាយរបស់"ផេស" បានបន្តថា សមត្ថភាពក្នុងការបង់ថ្លៃរបស់លោកអ្នកនឹងមិនក្លាយជាការរាំងស្ទះ ក្នុងតម្រូវការថែសុខភាពរបស់មនុស្សចាស់ឡើយ ។

លោកអ្នកដែលត្រូវការសេវានេះ អាចទៅទាក់ទងនៅតូប "អេលមិនឃែ" ដែលបើកនៅឱកាសបុណ្យអុំទូកថ្ងៃ១៥ខាងមុខនេះបាន ឬក៏ទាក់ទងមកទូរស័ព្ទ សាំង គីរីវដ្ឋ លេខ ៧៨១៧១៥ ៦៦ ៥៤ ឬ អ៊ីម៉ែល ksaint@elementcare.org ៕



តមកពីទំព័រទី ០៨

## បក្សប្រជាជនកម្ពុជាចាប់កំញើញ...

ងាយប៉ះពាល់ដល់កិត្តិយសនោះទេៈ "ប្រជាពលរដ្ឋសាមញ្ញក៏និយាយបានដែរ រឿងហ្នឹងគ្មានរណាគេប្តឹងទៅតុលាការអីអឺចឹងទេ ងាប់ហើយ! តើសេរីភាពបញ្ចេញមតិយ៉ាងម៉េចទៅបើអ្នកតំណាងរាស្ត្របញ្ចេញមតិប៉ុណ្ណឹងត្រូវគេដាក់ពិន័យចុះទម្រាំប្រជារាស្ត្រធ្វើម៉េចទៅ"។

ដោយមានបរិយាកាសនយោបាយតានតឹងលោក អ៊ុំ សំអាន ថានឹងបញ្ចប់កម្តៅនយោបាយនិងប្រើប្រាស់ "វប្បធម៌សន្ទនា" ដើម្បីបញ្ចប់ជម្លោះរវាងលោក និងប្រធានរដ្ឋសភា។ លោកក៏ផ្ញើលិខិតសុំអធ្យាស្រ័យ និងអត់ឱនឱ្យរូបលោកដោយក្តីអនុគ្រោះទៅសម្តេចប្រធាន ហេង សំរិន ហើយលោក អ៊ុំ សំអាន ឱ្យដឹងទៀតថា គម្រោងដែលលោកប្តឹងលោក ហេង សំរិន ទៅក្រុមប្រឹក្សាធម្មនុញ្ញក៏ត្រូវបញ្ចប់ដែរៈ "ខ្ញុំចង់បញ្ចប់បញ្ហាហ្នឹងជាមួយសម្តេច ហេង សំរិន ដើម្បីបើកផ្លូវកុំឱ្យមានការប្តឹងផ្តល់ទៅប្រព័ន្ធតុលាការ។ វារឿងត្រូវវែងឆ្ងាយទៀត បើសិនជាយើងមិនចរចាគ្នាទេ។ រឿងខ្ញុំត្រូវតែប្តឹងគាត់ទៅក្រុមប្រឹក្សាធម្មនុញ្ញគាត់ត្រូវតែប្តឹងខ្ញុំទៅតុលាការ ដូច្នេះយើងបញ្ចប់រឿងតែម្តងទៅ"។

តែមិនយ៉ាងដូច្នេះទេ សម្តេចប្រធាន ហេង សំរិន ដោយបានចារនៅលើលិខិតរបស់លោក អ៊ុំ សំអាន នឹងផ្តល់តែនូវការអធ្យាស្រ័យចំពោះលោក អ៊ុំ សំអាន ដោយបញ្ចប់ត្រឹមការដាក់ទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងសេចក្តីសម្រេចចុះថ្ងៃទី២៤ ខែកក្កដា។ គឺបានសេចក្តីថា ទណ្ឌកម្មខាងវិន័យពីប្រការ៨១នៃបទបញ្ជាផ្ទៃក្នុងរបស់សភានៅដដែលអត់មានលប់ចោលទេ ។ តាមបទបញ្ជាផ្ទៃក្នុងរបស់សភាគ្មានប្រការណាមួយអនុញ្ញាតឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាពិន័យឬដាក់ទោសពិន័យដល់សមាជិករដ្ឋសភាទេ ដូចមានចែងនៅប្រការ ៧៩ ថាៈ "ការបន្ទោស ឬការបន្ទោសហើយបណ្តេញចេញផង ត្រូវអនុម័តដោយអង្គសភាតាមវិធីលើកដៃឬបោះឆ្នោតចំហតាមសេចក្តីស្នើពីប្រធានរដ្ឋសភា"។ បើតាមបទបញ្ជាផ្ទៃក្នុងរបស់សភាកំហុសទាំងឡាយដែលអាចពិន័យបានទាល់តែសកម្មភាពអស់នេះធ្វើនៅពេលប្រជុំសភាពេញអង្គ ។ ចំពោះករណីរបស់លោក អ៊ុំ សំអាន គឺការបញ្ចេញគំនិតផ្សាយចេញតាមបណ្តាញព័ត៌មានសង្គមហ្វេសប៊ុក (Facebook) សោះ ។

ហើយ លោក អ៊ុំ សំអាន ក៏មិនត្រូវប្រឈមមុខនឹងផ្លូវតុលាការពីបទណាមួយឡើយ ពីព្រោះលោកមានអភ័យឯកសិទ្ធិ ដូចមានចែងនៅ មាត្រា ៨០នៃរដ្ឋធម្មនុញ្ញៈ


អ៊ុំ សំអាន

"តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។

តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួនឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។

ការចោទប្រកាន់ការចាប់ខ្លួន ការឃាត់ខ្លួនឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភាឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភាវៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភាឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ ដើម្បីសម្រេច។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។

ក្នុងករណីទាំងអស់ខាងលើនេះការឃុំខ្លួនការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាកប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល"។

ហេតុនេះលិខិតរបស់លោក អ៊ុំ សំអាន សុំអធ្យាស្រ័យពីសម្តេចប្រធានរដ្ឋសភា លោក ហេង សំរិន ដូចជាមិនមានវិជ្ជមានអ្វីសោះ ហើយជាពិសេសចំពោះមតិមហាជនប្រជាពលរដ្ឋខ្មែរនឹងអស់ និងអត់មានភាពកក់ក្តៅ និងទុកចិត្តលើគណបក្សសង្គ្រោះជាតិដោយឃើញគ្មានជំហរអ្វីច្បាស់លាស់ និងពិតប្រាកដសោះ។ នេះធ្វើឱ្យខ្ញុំនឹកឃើញដល់គណបក្សខ្លះពីមុនឮតែឡូឡាខ្លាំងៗដល់ ហ៊ុន សែន ស្រែកមួយវះមកក៏នាំគ្នារត់ទៅសុំទោសដែលធ្វើឱ្យប្រជាពលរដ្ឋឈប់គាំទ្រនឹងសមាជិកខ្លះខ្វះការទុកចិត្តក៏នាំគ្នារត់ចោល។

*លិមគិមយ៉ា*

*តំណាងរាស្ត្រ មណ្ឌលកំពង់ធំ*

*សមាជិកគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារនិងសវនកម្មនៃរដ្ឋសភា*


យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។

*លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!*





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់ ដែលរួមមាន៖*
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស)*
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប*
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
1-888-566-3526(ខ្សែទូរស័ព្ទឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* *លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត*

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ទាហានស្វះស្វែងរកប្រាក់បន្ថែមពីបណ្ដាក្រុមហ៊ុនឯកជន

**ដោយឃី សុវុឌ្ឍី | July 30, 2015**

រយៈពេលជាងប្រាំឆ្នាំបន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ដើមគំនិតឧបត្ថម្ភរដ្ឋាភិបាលដោយចងមេត្រីភាពក្រុមហ៊ុនឯកជននានាជាមួយអង្គភាពយោធាមកលោក ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារប្រទេសបានដឹកនាំសិក្ខាសាលាមួយកាលពីថ្ងៃពុធដោយស្នើសុំក្រុមហ៊ុននានាបន្តជួយផ្ដល់ប្រាក់ទៀត។

មន្ត្រីជាង៣០០នាក់មកពីកងយោធពលខេមរភូមិន្ទនគរបាលជាតិ និងតំណាងក្រុមហ៊ុនហើយនិងក្រសួងនានាបានជួបជុំគ្នានៅឯអគារវិមានសន្តិភាពរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីពិភាក្សាគ្នាអំពីការសន្យារបស់ខ្លួនក្នុងការជួយកងទ័ពផ្គត់ផ្គង់និងផ្ដល់នូវគ្រឿងបរិក្ខារ។

ក្នុងការប៉ុនប៉ងដើម្បីបង្កើនការផ្ដល់ប្រាក់ជួយកងយោធពលខេមរភូមិន្ទលោក ហ៊ុន សែន កាលពីខែកុម្ភៈឆ្នាំ២០១០ បានចាប់ផ្ដើមកម្មវិធីដែលនឹងឃើញក្រុមហ៊ុនធំៗបំផុតមួយចំនួនរបស់ប្រទេសនេះផ្ដល់អំណោយប្រាក់រាប់រយរាប់ពាន់ដុល្លារជួយអង្គភាពទ័ពទាំងឡាយ។

នៅពេលដែលការផ្ដើមគំនិតនេះបានចាប់ផ្ដើមមានក្រុមហ៊ុនចំនួន៤២ ដែលក្រុមហ៊ុនជាច្រើនក្នុងចំណោមនោះមានទំនាក់ទំនងជិតស្និទ្ធនឹងគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចបានសន្យាផ្ដល់អំណោយជួយអង្គភាពមួយចំនួន។

ក្នុងសុន្ទរកថាបន្ទាប់ពីសិក្ខាសាលាកាលពីថ្ងៃពុធនាយឧត្ដមសេនីយ៍ ទៀ បាញ់ បានរំឭកយ៉ាងហោចណាស់១០ក្រុមហ៊ុនដែលមានវត្តមានថាយោធានៅត្រូវការប្រាក់របស់ក្រុមហ៊ុននៅឡើយ។

លោកបានមានប្រសាសន៍ថា "បណ្ដាក្រុមហ៊ុនឯកជនដែលធ្វើជំនួញរកស៊ីសុខសាន្តក្នុងប្រទេសកម្ពុជា សូមជួយកងទ័ពដោយផ្ដល់មួយចំណែកតូចនៃប្រាក់ចំណេញរបស់អ្នក"។

នាយឧត្ដមសេនីយ៍ បាញ់ បានមានប្រសាសន៍ថា ភាគច្រើននៃប្រាក់អំណោយនឹងបានជាប្រយោជន៍ដល់ការដំឡើងប្រាក់ខែរបស់ទាហានដែលលោកបានមានប្រសាសន៍ថា នឹងត្រូវដំឡើងដល់មួយលានរៀល ឬប្រហែល២៥០ដុល្លារនៅឆ្នាំ២០១៨យ៉ាងយូរ។

លោកបានមានប្រសាសន៍ថា "យើងដឹងថាយើងមិនមានថវិកា ប្រសិនបើយើងមានវិញយើងនឹងផ្ដល់ភ្លាម"។

ប្រាក់ខែទាហានថ្នាក់ទាបបំផុតរបស់កងយោធពលខេមរភូមិន្ទសព្វថ្ងៃមានរវាង៣៥៥.០០០រៀលទៅ៥៣៣.០០០រៀល។

យោងតាមនាយឧត្ដមសេនីយ៍ បាញ់ បានឱ្យដឹងថា ប្រាក់ដែលប្រមូលបានពីក្រុមហ៊ុននានាក៏នឹងចំណាយលើការទិញស្បៀងអាហារនិងគ្រឿងផ្គត់ផ្គង់យោធាផងដែរ។

លោកបានមានប្រសាសន៍ថា "កាលពីមុននៅពេលដែលយើងត្រូវការសម្ភារសម្រាប់កងទ័ពក្រុមហ៊ុនមួយចំនួនបានផ្ដល់ប្រាក់ជួយយើង។ និយាយដោយស្មោះទៅឱ្យក្រុមហ៊ុន "ទិញសព្វាវុធ"។

តំណាងក្រុមហ៊ុនមិតហ្វូនជាក្រុមហ៊ុនទូរស័ព្ទចល័តធំបំផុតនៅកម្ពុជាតាមចំនួនអ្នកប្រើបានប្រាប់សិក្ខាសាលាថា ក្រុមហ៊ុនរបស់លោកបានផ្ដល់ប្រាក់ដ៏ច្រើនដល់យោធារបស់ប្រទេសកម្ពុជាក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ។

តំណាងរូបនេះដែលមិនប្រាប់ឈ្មោះបាននិយាយថា "ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៤ ក្រុមហ៊ុនមិតហ្វូនបានផ្ដល់អំណោយជាប្រាក់សរុប៤៦១.១០០ដុល្លារដល់មូលដ្ឋានទ័ពជើងទឹករាម និងកងពលតូចជើងទឹកលេខ៣១"។

ក្រុមហ៊ុនមិតហ្វូនជាសាខាមួយរបស់វៀតថែល (Viettel) ដែលគ្រប់គ្រងដោយយោធាវៀតណាម។

លោក សុខ គង់ ម្ចាស់ក្រុមហ៊ុនសូគីម៉ិច

**តទៅទំព័រទី១៣**



CheaDara, deputy commander of the Royal Cambodian Armed Forces, addresses military officers, police and company representatives during a workshop at Prime Minister Hun Sen's office building in Phnom Penh on Wednesday. (SivChanna/The Cambodia Daily)

# Military Seeks More Money From Private Firms

**BY KHY SOVUTHY | JULY 30, 2015**

More than five years after Prime Minister Hun Sen launched a government patronage initiative pairing private companies with military units, Defense Minister Tea Banh led a workshop Wednesday asking companies to keep the money coming.

More than 300 officials from the Royal Cambodian Armed Forces (RCAF), national police and representatives of companies and ministries met at the prime minister's office building to discuss their pledge to help arm, supply and outfit the military.

In an attempt to increase funding to RCAF, Mr. Hun Sen in February 2010 began the program that would see some of the country's biggest companies donate hundreds of thousands of dollars to individual army units.

When the initiative launched, 42 companies-many with close ties to the ruling CPP-pledged donations to specific units.

In a speech after Wednesday's workshop, General Banh reminded at least 10 companies present that the military was still in need of their cash.

"Private companies that do peaceful business in Cambodia, please help the army by giving a small part of your profits," he said.

Gen. Banh said that much of the donated money would go to increasing soldiers' monthly salaries, which he said would be raised to 1 million riel, or about $250, by 2018.

"We know we do not have the budget, if we had it we would give it immediately, " he said.

The monthly salaries of RCAF's lowest-ranking soldiers is now between 355,000 riel (about $88.75) to 533,000 riel (about $133.25).

According to Gen. Banh, the money collected from the companies would also go toward purchasing food and military supplies.

"In previous times, when we needed materials for the army, some of the companies provided us with money," he said. "Honestly, [the companies] buy weapons."

A representative of Metfone, Cambodia's largest mobile phone provider by subscribers, told the workshop that his company had given substantial funds to Cambodia's military in recent years.

"From 2010 until 2014, Metfone donated a total of $461,100 to the Ream Naval Base and Navy Platoon 31," said the representative, who did not give a name.

Metfone is a subsidiary of Viettel, which is wholly owned by the Vietnamese military.

Sok Kong, owner of Sokimex and an ally of Mr. Hun Sen, also sent a representative to tell Wednesday's meeting that the petroleum company had donated $350,000 to RCAF since 2010.

Contacted later in the day, MongReththy, a CPP senator and president of the MongReththy Group, said his company had donated substantially to the military over the years. However, he did not provide a concrete figure.

"I donated food supplies to the armed forces along the border in Koh Kong province because I think that they were at the front lines and lack food," he said.

"I also donated to them because I wanted to connect the private sector with the armed forces, especially because I am just grateful that the armed forces defend our nation."

Despite the presence of heavy-hitting CPP-friendly businesses at the workshop, which was also presided over by Deputy Prime Minister Man Sam An, Gen. Banh insisted the military was unbiased in how it served the country.

"The armed forces must be neutral toward all political parties," he said.

However, Deputy RCAF Commander CheaDara said the military was indeed a steward for the ruling party.

"SamdechTecho [Hun Sen] said, and I remember this speech on July 23, if we said correctly, the army belongs to the Cambodian People's Party because Samdech Techo took care and led the army," General Dara said.

"The army belongs to the Cambodian People's Party…but the army also has other duties: to defend the constitutional law, king and **Continued to page 23**

## តមកពីទំព័រទី ១២ ទាហានស្វះស្វែងរកប្រាក់បន្ថែម...

ដែលជាសម្ពន្ធមិត្តរបស់លោក ហ៊ុន សែន ក៏បានបញ្ជូនតំណាងមួយរូបដើម្បីប្រាប់សិក្ខាសាលាកាលពីថ្ងៃពុធថា ក្រុមហ៊ុនប្រេងនេះបានផ្តល់អំណោយ៣៥០.០០០ដុល្លារដល់កងយោធពលខេមរភូមិន្ទចាប់តាំងពីឆ្នាំ២០១០មក។

ទាក់ទងនៅថ្ងៃដដែលនោះ លោក ម៉ុង ឫទ្ធី សមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប បានមានប្រសាសន៍ថា ក្រុមហ៊ុនរបស់លោកបានផ្តល់អំណោយយ៉ាងច្រើនក្រាស់ក្រែលដល់យោធាក្នុងពេលជាច្រើនឆ្នាំនេះ។ ក៏ប៉ុន្តែលោកមិនបានផ្តល់តួលេខច្បាស់លាស់ទេ។

លោកបានមានប្រសាសន៍ថា "ខ្ញុំបានជួយគ្រឿងផ្គត់ផ្គង់ស្បៀងអាហារដល់កងទ័ពនៅតាមបណ្តោយព្រំដែនក្នុងខេត្តកោះកុង ពីព្រោះខ្ញុំគិតថា ពួកគេស្ថិតនៅជួរមុខ ហើយខ្វះស្បៀងអាហារ"។

"ខ្ញុំក៏បានផ្តល់អំណោយដល់ពួកគេដែរ ពីព្រោះខ្ញុំចង់ផ្សារភ្ជាប់វិស័យឯកជនជាមួយកងទ័ពជាពិសេស ពីព្រោះខ្ញុំដឹងគុណដែលកងទ័ពការពារប្រទេសជាតិរបស់យើង"។

ទោះជាមានវត្តមានក្រុមហ៊ុនជិតស្និទ្ធនឹងគណបក្សប្រជាជនកម្ពុជានៅសិក្ខាសាលាដែលមានឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន ជាអធិបតីក៏ដោយ ក៏នាយឧត្តមសេនីយ៍ បាញ់ បានបញ្ជាក់ថា យោធាមិនបានលម្អៀងទេ។

លោកបានមានប្រសាសន៍ថា "កងទ័ពត្រូវតែអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយទាំងអស់"។

ក៏ប៉ុន្តែ លោក ជា តារា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទបានមានប្រសាសន៍ថា យោធាពិតណាស់ស្មោះនឹងគណបក្សកាន់អំណាច។

នាយឧត្តមសេនីយ៍ តារា បានមានប្រសាសន៍ថា "សម្តេចតេជោឱ្យ ហ៊ុន សែន បានមានប្រសាសន៍ ហើយខ្ញុំចាំសុន្ទរកថានេះនៅថ្ងៃទី២៣ ខែកក្កដាថា ប្រសិនបើយើងនិយាយឱ្យត្រឹមត្រូវ កងទ័ពជារបស់គណបក្សប្រជាជនកម្ពុជា ពីព្រោះសម្តេចតេជោបានយកចិត្តទុកដាក់និងបានដឹកនាំកងទ័ព"។

លោកបានបន្ថែមថា "កងទ័ពជារបស់គណបក្សប្រជាជនកម្ពុជា ប៉ុន្តែកងទ័ពក៏មានភារកិច្ចផ្សេងទៀត ការពារច្បាប់រដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រនិងរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោត"។

លោកស្រី ជា វណ្ណាត អ្នកវិភាគនយោបាយ និងជាអតីតប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម បានមានប្រសាសន៏ថា វិស័យឯកជនផ្តល់ប្រាក់ជួយយោធាពិតណាស់នាំឱ្យមានភាពអនុគ្រោះនិយម។

លោកស្រីបានមានប្រសាសន៏ថា "ប្រាកដហើយ វានឹងអឺចឹង។ ដូចភាសិតខ្មែរនិយាយថា កុំខាំដៃដែលចិញ្ចឹមអ្នក"។

និត(រាយការណ៏បន្ថែមដោយ Chris Mueller)


# Neighborhood Physical Therapy




337 Westford Street. Lowell, MA 01851

978-455-4320

- Auto Accident Injuries
- Work Injuries
- We provide transportation

- គ្រោះថ្នាក់ចរាចរណ៏
- គ្រោះថ្នាក់នៅកន្លែងធ្វើការ
- យើងខ្ញុំមានផ្តល់ការជញ្ជូនសម្រាប់លោកអ្នក

# វិជ្ជាស្ថានរៀន ថែសម្ផស្សមុខនិងត្រចក

## Chelmsford Beauty Academy

60 Chelmsford St.,2nd Floor Chelmsford, MA. 01824

Tel: (978)328-9722 ឬ (978) 250-4488





- យើងខ្ញុំបានបើកវគ្គបង្រៀនធ្វើត្រចក និងថែសម្ផស្សមុខ គ្រូបង្ហាត់ មានការដកពិសោធន៏ច្រើនឆ្នាំ មានថ្នាក់រៀនក្រៅម៉ោង និងពេញម៉ោង៧ថ្ងៃក្នុង១សប្តាហ៏
- យើងខ្ញុំបើកវគ្គសិក្សា៣០០ម៉ោង (ក្នុងរវេលា២ខែកន្លះ) សម្រាប់ថ្នាក់ថែសម្ផស្សមុខ និងវគ្គ១០០ម៉ោង (ក្នុងរវេលា៣អាទិត្យ)
- សម្រាប់ថ្នាក់ធ្វើត្រចក។
- សូមចុះឈ្មោះជាប្រញាប់ !
- (តម្លៃសិក្សាក្រចក ៩០០ដុល្លារ)
- (តម្លៃសិក្សាថែសម្ផស្ស ២៥០០ដុល្លារ)

ជួយណែនាំរកការងារធ្វើ ពេលចប់ការសិក្សា

Chelmsford Beauty Academy មានចម្ងាយ៥នាទីពីក្រុង Lowell,
និង១៥នាទីពីក្រុង Lawrence, ចម្ងាយ១០នាទីពី Burlington Mall, និង១០នាទី Andover.

ព័ត៏បន្ថែមទាក់ទងជាមួយយើងខ្ញុំថ្ងៃនេះទូរស័ព្ទលេខ : (978)328-9722 ឬលេខ : (978)250-4488

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# តារាហូលីវូដ អ៊ែនជែលីណា ចូលី ចាប់ផ្ដើមការងារ ផលិតភាពយន្តនៅភ្នំពេញ

**ដោយៈ សៃម៉ុន ហេនឌឺរសិន** | **July 29, 2015**

តារាហូលីវូដ អ៊ែនជែលលីណា ចូលី បាន មកដល់រាជធានីភ្នំពេញកាលពីម្សិលមិញដើម្បី ចាប់ផ្ដើមការងារផលិតខ្សែភាពយន្តនិយាយជាភាសាខ្មែរបង្ហាញពីជីវិតនៅក្នុងសម័យខ្មែរក្រហម រឿង "មុនដំបូងខ្មែរក្រហមសម្លាបឪពុករបស់ខ្ញុំ" ដែលនឹងសហការផលិតដោយលោក ប៉ាន់ រិទ្ធី ផលិតករភាពយន្តដែលជាបេក្ខភាពពានរង្វាន់អូស្កា។

អ្នកនាង ចូលី បានសរសេរប៉្រូលរួមគ្នា យោងតាមសៀវភៅដែលជាស្នាដៃរបស់អ្នកស្រី លឿង អ៊ឹង ហើយនឹងដឹកនាំខ្សែភាពយន្តឱ្យក្រុមហ៊ុន Netflix ជាក្រុមហ៊ុនផលិតភាពយន្តដាក់តាមប្រព័ន្ធអ៊ីនធឺណិត ដែលត្រូវបានប្រកាសកាលពីថ្ងៃសុក្រថ្ងៃតែមួយដែលតារាហូលីវូដរូបនេះបានមកដល់កម្ពុជា ដើម្បីចាប់ផ្ដើមដំណើរការមុនការផលិត។

កាលពីម្សិលមិញ អ្នកស្រីបានទៅទស្សនាមជ្ឈមណ្ឌលបូផាណា ក្នុងរាជធានីភ្នំពេញជាមួយលោក ប៉ាន់ រិទ្ធី ដែលបានបង្កើតមជ្ឈមណ្ឌលនេះឡើងដើម្បីអភិរក្សកេរដំណែលសោតទស្សន៍របស់កម្ពុជា និងដែលភាពយន្តរបស់លោកមានចំណងជើងថា "កង្វះរូបភាព" (The Missing Picture) ផលិតនៅឆ្នាំ២០១៣ ដែលឆ្លុះបញ្ចាំងពីសម័យ ប៉ុល ពត ត្រូវបានជ្រើសរើសយកទៅប្រកួតដណ្ដើមពានរង្វាន់អូស្កា។ អ្នកស្រី ចូលី បាននិយាយថា អ្នកថែរក្សាប័ណ្ណសារនៅមជ្ឈមណ្ឌលបូផាណា និងជួយធានាថា ភាពយន្តថ្មីរបស់អ្នកស្រីជាភាពយន្តថត និងដកស្រង់តាមខ្លឹមសារសាច់រឿងក្នុងសៀវភៅនេះពិតៗ។

យោងតាមសេចក្ដីប្រកាសព័ត៌មានបានឱ្យដឹងថា "ការងារលម្អិតរបស់ពួកគេដើម្បីស្ដារប័ណ្ណសារពីអតីត និងធ្វើការជាមួយយុវជន និងអ្នកស្ម័គ្រចិត្តដើម្បីសម្លឹងអនាគតផ្អែកលើគោលបំណងរួមគឺជាការជំរុញទឹកចិត្ត ហើយខ្ញុំមានកិត្តិយសណាស់ដែលបានធ្វើការជាមួយលោក ប៉ាន់ រិទ្ធី ដែលខ្ញុំចង់រៀនសូត្រជាខ្លាំង"។

អ្នកស្រី ចូលី បាននិយាយថា ក្រុមការងាររបស់អ្នកស្រីនឹងចំណាយពេល៣ខែក្រោយដើម្បីស្វែងរកទីតាំងថត និងជ្រើសរើសតួសម្ដែង ហើយថា ភាពយន្តនេះនឹងចាប់ផ្ដើមថតពីខែវិច្ឆិកា ដល់ខែមករា។

អ្នកស្រីបាននិយាយថា "គ្រប់ឈុតសម្ដែងទាំងអស់នឹងត្រូវស្រាវជ្រាវដើម្បីឱ្យប្រាកដថា វាត្រឹមត្រូវតាមប្រវត្តិសាស្ត្រ ហើយមិនត្រឹមតែជាការគោរពដល់អ្នកស្រី លឿង អ៊ឹង និងក្រុមគ្រួសាររបស់គាត់ប៉ុណ្ណោះទេ គឺគោរពដល់អ្នកទាំងឡាយដែលទទួលរងការឈឺចាប់ក្នុងសម័យក្រហមទៀតផង"។



អ្នកស្រី អ៊ែនជែលីណា ចូលី និងលោក ប៉ាន់ រិទ្ធី ផលិតករភាពយន្តខ្មែរពេលទៅទស្សនានៅមជ្ឈមណ្ឌលបូផាណា កាលពីម្សិលមិញ ដើម្បីដំណើរការផលិតភាពយន្តរឿង "មុនដំបូងខ្មែរក្រហមសម្លាប់ឪពុកខ្ញុំ" ដែលស្ដីពីជីវិតក្នុងសម័យខ្មែរក្រហម។ រូបថតៈ មជ្ឈមណ្ឌល បូផាណា

ការិយាល័យរបស់អ្នកស្រី ចូលី បានឱ្យដឹងថា សៀវភៅរបស់អ្នកស្រី លឿង អ៊ឹង រៀបរាប់ពីជីវិតរស់នៅក្នុងរបបខ្មែរក្រហម និងការរត់គេចពីរបបខ្មែរក្រហមចាប់ពីអ្នកស្រីអាយុ៥ឆ្នាំដល់៨ឆ្នាំនោះក៏នឹងមកប្រទេសកម្ពុជា ដើម្បីជួយរៀបចំការផលិតផងដែរ។ បច្ចុប្បន្ននេះ ក្រុមហ៊ុន Netflix មិនទាន់មានវត្តមាននៅកម្ពុជានៅឡើយទេ ប៉ុន្តែរឿង "មុនដំបូងខ្មែរក្រហមសម្លាប់ឪពុកខ្ញុំ" នឹងមានការដាក់បញ្ចាំងនៅតាមរោងភាពយន្តមួយចំនួនក្នុងប្រទេសកម្ពុជានិងនៅបរទេស។

ការិយាល័យរបស់អ្នកស្រី ចូលី បានឱ្យដឹងថា "នឹងមានការដាក់បញ្ចាំងលើកដំបូងនៅក្នុងប្រទេសកម្ពុជា។ អ្នកស្រី ចូលី និងក្រុមគ្រួសារនឹងអញ្ជើញចូលរួមក្នុងការដាក់បញ្ចាំងលើកដំបូងដោយផ្ទាល់ និងធ្វើបទបង្ហាញអំពីខ្សែភាពយន្តនេះដល់ទស្សនិកជនខ្មែរ"៕ **សារុន**

# Angelina Jolie Begins Work on New KR Film

**BY SIMON HENDERSON | JULY 29, 2015**

Angelina Jolie Pitt was in Phnom Penh on Tuesday to begin work on a Khmer-language film based on bestselling Khmer Rouge survival memoir "First They Killed My Father," which will be co-produced by Oscar-nominated filmmaker RithyPanh.

Ms. Jolie Pitt co-wrote the script with the book's author, Loung Un, and will direct the movie for online streaming company Netflix, it was announced Friday, the same day that the actress arrived in Cambodia to begin pre-production.

On Tuesday, she visited the Bophana Center in Phnom Penh alongside Mr. Panh, who founded the center to help preserve Cambodia's audiovisual heritage and whose 2013 cinematic memoir of the Pol Pot era, "The Missing Picture," was nominated for an Academy Award.

Ms. Jolie Pitt said archivists at the Bophana Center would help ensure that her new film was an authentic interpretation of the book and its setting.

"Their detailed work to restore the archives of the past and work with young people and volunteers to look forward to the future based on a shared purpose is inspiring, and I am honoured to work with RithyPanh from whom I have so much to learn," she said, according to a press release.

Ms. Jolie Pitt said her crew would spend the next few months scouting locations and auditioning actors, and that shooting will take place from November to January.

"Every event [will be researched] to make sure it is historically accurate and will pay respect not only to Loung Un and her family but to every single individual who suffered under the Khmer Rouge," she said.

Ms. Un, whose book is an account of living under and escaping the Khmer Rouge between the ages of five and eight, will also come to Cambodia to assist with the production, Ms. Jolie Pitt's office said.

Netflix is currently unavailable in Cambodia, but "First They Killed My Father" will have a limited cinema release in Cambodia and abroad.

"There will be a Cambodian premiere. Ms Jolie Pitt and family will personally come to the premiere and present the film to Cambodian audiences," her office said.

**Continued from page 03**

# About the Town...

SampasPavillionin Lowell, MA at 7:00pm. Don't miss out on The Classic Car Show that begins at 6:00pm right before the concert! Enjoy a fun-filled night out with the family, all free of cost. The August calendar is as follows:

- The Tony O Band- Monday August 10, 2015
- Classic Trax- Monday August 17, 2015
- Sturdy Moss- Monday August 24, 2015
- FREEVOLT- Monday August 31, 2015

There are also a number of local musicians performing at NARA Park at 25 Ledge Rock Way in Acton. Bring the family and enjoy a fun evening under the stars. Concert is from 6:30-8pm

- Dell Smart & Exit-August 13

We also hope to see you at the Southeast Asian Water Festival at Sampas Pavilion in Lowell, Mass on Saturday, August 15, 2015. This festival is dedicated to the preservation, protection and sharing of cultural heritages of the Southeast Asian Communities. Come enjoy the blessings of the water, watch traditional boat races, try some new cuisine and enjoy the craft area.

For more information on the events listed above or any other questions you may have please visit our website @ www.merrimackvalley.org

**Until next time,**


19TH ANNUAL LOWELL
SOUTHEAST ASIAN
WATER FESTIVAL
BOAT RACES
LIVE ENTERTAINMENT
AUTHENTIC FOOD
MERCHANDISES
INFORMATION BOOTHS
CULTURAL PERFORMANCES
PAPAYA SALAD TASTING CONTEST
&
MANY MORE
GREAT EATS!
VISIT US AT:
LOWELLWATERFESTIVAL.ORG
AUGUST 15, 2015
CONTACT INFO:
LOWELLSEAWATERFESTIVAL@GMAIL.COM
SAVE THE DATE
FLYER DESIGN BY: RICKY MAO -ricmao26@gmail.com

**adventures await**

Greater Merrimack Valley
Convention & Visitors Bureau

For more fun things **to see & do** and great places **to eat & stay**, visit...
**www.merrimackvalley.org**

KhmerPost USA
សារព័ត៌មាន ខ្មែរប៉ុស្ត៍ ស.រ.អា

ហាងកាហ្វេ ...
Morning S...
Convenience & Sandw...
Coffee-Bubble Tea – Deser...
Monday-Thursday 7am-8pm
Friday-Sunday 6am-8pm
(978) 710-6598
716 Middlesex St. #2-3 Lowe...

# ផែនទីបង្ហាញពីប្រ...

## Southeast Asian Wat...




ក្រុមហ៊ុនទេសចរណ៍ តោពី
TORPI TRAVEL
លក់សំបុត្រយន្តហោះក្នុង និងក្រៅប្រទេស
តម្លៃពិសេស-សេវាកម្មល្អ-ធានាគុណភាព
PHONE: (978) 332-1797 - FAX: (978) 455-2533
www.TORPINFO-COTAC@TORPINfO

ផ្សារហុងកុង
**Hong Kong Market**
ពិសេសមានលក់បន្លែគ្រប់មុខ និងមានលក់ម្ហូប
ខ្មែរ ថៃ ឡាវ និង ចិន
Open 7 days. 9am - 9pm
289 Westford St, Lowell, MA 01851
**978-452-7391**

BOKOR AUTO CENTER
EST. 1987 LOWELL, MA
DAVID ROS & RA ROS
OWNERS/TECHNICIANS
31 DIX STREET
LOWELL, MA 01852
TEL: 978-459-8121
FAX: 978-654-6314
bokorautoctr@gmail.com
MASSACHUSETTS VEHICLE CHECK
STATION NO. PB014637
MON-FRI 8:30AM - 5PM SAT 8:30 - 2PM
រោងជាងជួសជុលរថយន្តបូកគោ



Valaurie Lor
Stylist/Manager
Sros Salon
"Youniquely Beautiful You"
Hair cut, Men's Fade, Color, Highlights, Ombre, Perm
Prom & Special event Up-Do's, Makeup, Waxing
507 Dutton Street
Lowell, MA 01854
(978) 856-7337
Appointment/ Walk-Ins Welcome
www.Facebook.com/srossalon
www.youniqueproducts.com/valaurielor

ភោជនីយដ្ឋាន សុភមង្គលថ្មី
New Happiness Restaurant
Open from 7:30AM-9:00PM
ម្ហូបខ្មែរពិត។
6 Branch Street Lowell. MA 01851
**(978) 454-4727**

ភោជនីយដ្ឋានពិភពថ្មី
PEEPHUPTMEI RESTAURANT
(978) 937-2919
Huthentic Chinese, Cambodian, Vietnames Cuisine
**278 Branch Street, Lowell, MA 01851**

THE LOW...
ហាង...
Wedding De...
Sereyso...
Flor...
Tel (978) 455-0999
Cell (978) 259-8627
Mon-Sat 9:00AM-6:00PM
Sun 10AM-5PM

យព្រឹក
Star
wich Shop
rts – Grocery
ell, MA 01851

PHNOM PENH PECH JEWELRY
Tiệm Vàng
(978)710-4844
Fine Jewelry:18K -24K
Diamond * Watches * Retail * Reapair
717 Middlesex Street
Lowell, MA 01851
Open 6 Days A Week
10:00am To 6:00pm
Closed Wednesday

ភោជនីយដ្ឋាន ភ្នំពេញ
Phnom Penh Restaurant
Fine Cambodian, Chinese, Thai, and Vietnamese Cuisine
Open 7 Days 8:00AM -8:00PM
Telephone : 978-275-0999
309 Westford St.
Lowell, MA 01851



The Law Office of Louis S. Haskell
YOUR ACCIDENT TEAM
978.459.8359

# ណាំងទូក និងក្រុងខ្មែរ

## er Festival August 2015




ផ្សារឡាក់គី
Lucky Asian
Market
4 Pine Street. Lowell, MA 01851
978-934-9999

Red Rose Restaurant
Dine In / Take Out
716 Middlesex Street
Lowell, MA 01851
Tel: 978-452-5400
Open 7 Days a Week 8:00am - 8:00pm

## Community Resources Information

**Cambodian Mutual Assistant Association**
465 School Street. Lowell, MA 01851. **Tel. 978-454-6200**

**Cambodia Town Lowell, Inc.**
16 Pine Street. Suite 13. Lowell, MA 01851. **Tel. 978-364-1911**

**Lowell General Hospital**
295 Varnum Ave., Lowell, MA 01854. **Tel. 978- 937-6000**

**Lowell Fire Department**
99 Moody St, Lowell, MA 01852. **Tel. 978 459-5553**

**Lowell Police Department**
50 Arcand Dr, Lowell, MA 01852. **Tel. 978- 937-3200**

**Metta Health Center**
135 Jackson St, Lowell, MA 01852. **Tel. 978-441-1700**

BANGKOK MARKET ផ្សារបាងកក
179 Chelmsford St, Lowell, MA 01851
978-452-5852 Open 7 days • 9am - 7pm

AccuCare
Home Care Agency
Group Adults Foster Care Program
ក្រុមហ៊ុនជំនួយថែទាំសុខភាពតាមផ្ទះ
មិនគិតថ្លៃដោយ MassHealth
និយាយភាសាខ្មែរ
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

WELL FLOWER HOUSE
ផ្កាឡូវែល
ecoration & Flower Arrangement
phana Youk
ris/Artist
2009 Chelsmaford St.
Lowell, MA 01851
lowellflowerhouse@yahoo.com
www.thelowellflowerhouse.com

VMART
INTERNATIONAL MARKET
VARIETY
FRESHNESS
GREAT PRICES
125 Church Street, Lowell, MA
• Open daily from 9am – 7pm
www.vmartinternationalmarket.com
978-710-6237

មានលក់ហ្វូនខត ចេញថ្លៃទឹកភ្លើង
និងផ្ញើរលុយ
The 99 Store
Money Transfer – Bill Payment – Phone Cards
180 Liberty St. Lowell, MA
978-454-8679
KimsengSeng, Manager



MD Realty
BOPHA PEOU
English-Khmer-Vietnamese
Realtor®
Notary
Cell: 978-427-7726
34 D Constitution Drive
Marblehead MA 01945
Email: bophapeou.bp@gmail.com

# វត្តមណ្ឌលពុទ្ធសាសនាតំបន់ញូអ៊ិងឡិន្ត

## THE BUDDHIST CENTER OF NEW ENGLAND. Inc

252 Public Street, Providence, RI 02905
Tel: (401) 454-4633

## សេចក្តីបវារណា

ខ្ញុំព្រះករុណា អាត្មាភាពភិក្ខុឃោសកោវិសិទ្ធិ **យៀង សុចិត្រា** ជាចៅអធិការ និងគណៈកម្មការវត្ត **វត្តពុទ្ធមណ្ឌល**បានព្រមព្រៀងគ្នានឹងតម្លើងដំបូលអាគារជាដំបូលព្រះវិហារ ឲ្យទៅតាមរចនាបថខ្មែរដូចមាននៅក្នុងរូប គំនូរនេះស្រាប់ មានបណ្តោយ **138ft** ទទឹង**50ft** និងកំពស់**21ft** ពីលើអាគារចាស់ឲ្យសមទៅតាមលក្ខណៈជាវត្តអារាម សំរាប់ឧទ្ទិសជាប្រយោជន៍ព្រះពុទ្ធសាសនា និងបំរើសង្គមទូទៅ។ ដើម្បីបានសម្រេចនូវគំរោងនេះ ត្រូវការចំណាយថវិកា អស់ម្ភៃម៉ឺនដុល្លារ សហរដ្ឋអាមេរិក ($200,000.00) ដែលនឹងគិតទាំងថ្លៃជាង និងជាវសម្ភារៈ។

អាស្រ័យដូចបានប្រគេននិងចំរើនពរខាងលើនេះ សូមព្រះតេជគុណ លោកប្រុស លោកស្រី លោកយាយ លោកតា ពុទ្ធបរិស័ទទាំងអស់ សូមមេត្តាចូលរួមបន្តការឧបត្ថម្ភថវិកាតាមកម្លាំងសទ្ធា ដើម្បីបានសំរេចជាស្ថាពរនៅពេលឆាប់ៗខាងមុខនេះ។

សូមប្រសិទ្ធិពរ ប្រគេនព្រះតេជគុណ ជូនលោក លោកស្រី លោកយាយ លោកតា និងពុទ្ធបរិស័ទទាំងអស់ទទួលបាននូវពុទ្ធពរ បួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយហោង៕

ធ្វើនៅវត្តមណ្ឌលពុទ្ធសាសនា ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥

**ប្រធានគណៈកម្មការនាយក** — **លោក សៅ ធា**

**ព្រះចៅអធិការវត្ត** — **ឃោសកោវិសិទ្ធិ យៀងសុចិត្រា**

## ꩜ Requesting for donation ꩜

I, Venerable Sochettra Yieng, Head Buddhist Monk, and Board of Directors of The Buddhist Center of New England, Inc. are in an agreement to build new addition to the roof of the temple building sized 138ft x 50ft x 21ft in a Cambodian and traditional temple (Vihear) style seen in our Cambodia homeland. To complete this project, the temple is in need of $200,000.00 to buy the materials and labor

For the aforementioned, we would like to request for your generous donation to fulfill this goal.

May all of you be blessed with 4 kinds of Buddha's Blessing: Long and Prosperous Life, Beauty and Prestige, Joy and Happiness, and Abundance of Strength and Wealth!

| No/ | សម្ភារៈ | អស់ចំនួន | អស់ថវិកា | ១ថ្លៃ | ២ |
|---|---|---|---|---|---|
| 1 | ដុំឥដ្ឋស៊ីម៉ងCement Bloc | 2000ដុំ | $10,000 | 1ដុំ $5 | |
| 2 | Cement ស៊ីម៉ង់ | 400ថង់ | $10,000 | 1ថង់$25 | |
| 3 | Trust ឈើផ្តោង | 300ដើម | $30,000 | 1 $100 | |
| 4 | Plywood ក្តារ | 450បន្ទះ | 22,500 | 1បន្ទះ$50 | |
| 5 | Nail ដែកគោល | 200 ប្រអប់ | $8,000 | 1 $40 | |
| 6 | Roofing Felt<br>កៅស៊ូក្រាលដំបូល | 100 ដុំ | $4,000 | 1ដុំ $40 | |
| 7 | Shingles ដុំបូលគ្រួស | 2000ដុំ | $100,000 | 1ដុំ $50 | |
| 8 | ហោជាងក្បាច់ខាងមុខ | បី | $4,000 | $12,000 | |
| 9 | Column សសរ | 60 ដើម | $9,000 | 1 $150 | |
| 10 | ជួយដំបូលជាម៉ែត្រការ៉េ | ១ការ៉េ | $50 | | |
| | ហោជាងក្បាច់ ជើងពាន់ទ្រ | ត្រៃបិដក៤ | $5,000 | $20,000 | |
| | ក្បាច់រូបនាគដំបូលថ្នាក់លើ | ៨នាគ | $1,500 | $12,000 | |
| | ក្បាច់រូបនាគដំបូលថ្នាក់ទី២ | ៦នាគ | $1,200 | $7,200 | |
| | Electric & Fire Alarm | | | | |
| | Heat & AC | Had sponsor | Already | | |

*សូមគួសប្រអប់មួយណា ដែលមានសទ្ធា!*







## Donation Form

Dear Bhante,

I am herewith enclosing a check for donation of_______________dollars for building new addition to the roof of The Buddhist Center of New England, Inc.

Name of donator: First name: ______________________________
Last name: ______________________________
Address______________________ ______________________
City________________State______Zip code ____________________.
Home phone:________________Cell ______________________
E-mail: ______________________________
Signature: ______________________________

Date: ________________

*☞Contribution can be made to: "BCNE" or The Buddhist Center of New England, Inc. 252 Public Street, Providence, RI 02905*

*We are a 501 (C) (3) not-for-profit organization. Your contribution is tax deductible. Receipt will be issued to acknowledge for your kind contribution.*

Respectfully yours,

Venerable **Sochettra Yieng**
Head Buddhist Monk

Mr. **Thea Sao**
President of the Board of Directors

# មេធាវីជំនាញស្ដីពីអាណ្វស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្ដាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្ដីប្រពន្ធ ឬគូរដណ្ដឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្ដីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

## Thomas Stylianos Law Offie

**287 Appleton Street, Suit 205 Lowell, MA 01852**

# Tel: 978-459-5000

**E-mail: Tom@stylianoslaw.com**

Attorneys' only licensed in Massachusetts

ព័ត៌មានខ្លីៗ ២

# ក្រុងខ្មែរផ្លូវឌីវែសហ្វីងឌ៍កំពុងកែរតែពាណិជ្ជករទិទាន

## Business owner complains at Cupple Square

**ដោយ ខ្មែរផុស**

**ឡូវែល:** សប្ដាហ៍មុននេះ ការដ្ឋានកែរលំអរ នៅ"ខិបប៉ុលស្គែរ"បានចាប់ផ្ដើមដូចគម្រោង នៅពេលដែលគេដាក់ធុងក្រហមផ្ដើមបង្ហាញពីអ្វីដែលត្រូវរុះរើនោះ តំបន់ពាណិជ្ជកម្មខ្មែរបែរក្លាយទៅជាចង្អៀតស្ទើរឡានចៀសគ្នាមិនបាន។ តើអ្នកម្ចាស់ហាងគេយល់យ៉ាងណា?



មេធាវី ល្វី ហាសស្កាល់

លោកមេធាវី ល្វី ហាស្កិល ដែលមានការិយាល័យនៅទីនោះ និយាយថា "ជាគម្រោងដែលគួរបំរុងធ្វើនោះ អន់ណាស់" លោកថា អ្នកដែលចង់ចូលមកការិយាល័យខ្ញុំទៅថ្ងៃមុខនឹងវាងទៅកាត់តាមធានាគារដែលជាផ្លូវឯកជន ទើបមកបាន។ រីឯចំណតឡានដែលគេបំរុងដាក់"មីទ័រ"នៅខាងក្រោយផ្លូវ"វែសហ្វីដ"នោះ នឹងចាល់អាចនឹងមករកចតដល់កន្លែងចតឡានខ្ញុំដែលនឹងរំខានដល់បុគ្គលិកមកធ្វើការនៅអាគារជាមួយខ្ញុំនៅទីនេះ...។ ខ្ញុំបានទូរស័ព្ទទៅរកប្រាប់អ្នកគ្រប់គ្រងសាលាក្រុងដែរ តែមិនមាននរណាឆ្លើយមកខ្ញុំវិញទេ...។




ក្រុងខ្មែរផ្លូវ វែសហ្វីដ

ម្ចាស់ហាង"ឡាក់គី" គាត់រអ៊ូថា ភ្ញៀវរបស់ខ្ញុំស្ទាត់ឈឹងតាំងតែពីគេគូសពីលើថ្នល់នឹងដាក់ធុងក្រហមពេលណាមក... លោក រ៉ាឌី ម៉ម ថាគំនិតកែទម្រង់"ខុបប៉ុល់ស្គែរ"នេះជាគំនិតរបស់គាត់ពីមុនគេអាចឈប់ឡានទម្លាក់ឥវ៉ាន់មុខហាងបាន ហើយភ្ញៀវក៏អាចឈប់នឹងទិញម្ហូបបាន១៥នាទីដែរ មិនរំខាននរណាទេ... ផ្លូវចំហៀងនៃអាគារម្ខាងបិទជិតឈឹង រីឯម្ខាងទៀតចង្អៀតមិនអាចចតឡានដោយមិនស្ទះចរាចរបានទេ តើខ្ញុំនឹងរកស៊ីទៅមុខរបៀបណា?

លោក ហាស្កិល បានប្រាប់បន្តពីយោបល់លោកថា ខ្ញុំមិនយល់ថា ហេតុអ្វីក៏គេត្រូវកែទម្រង់តំបន់នេះទេ... បើថា ដោយសារចំនួនគ្រោះថ្នាក់ច្រើនខ្ញុំជាមេធាវីខាងគ្រោះថ្នាក់ចរាចរស្រាប់ខ្ញុំអាចប្រាប់បានថា កន្លែងដែលមានគ្រោះថ្នាក់ច្រើនជាងគេមាន៣តែមិនមែននៅ"ខិបប៉ុលស្គែរ"នេះទេ។




លោក អាដាម ព្រិល ជាអនុប្រធានសមាគមពាណិជ្ជករក្នុងតំបន់បានសន្និដ្ឋានថា សាលាក្រុងគេបានធ្វើអ្វីដែលគេត្រូវធ្វើបានសមរមហើយ គេបានសួរយោបល់គ្រប់គ្នាមុនពេលចាប់ផ្ដើមការដ្ឋាន តែមិនមាននរណាប្រឆាំងនឹងគម្រោងនេះទេ... ចំពោះខ្ញុំដែលមិនមានហាងនៅទីនោះនឹងមើលបញ្ហាមិនបានជ្រៅដូចអ្នកដែលរស់នៅក្នុងតំបន់នោះទេ ម្ចាស់ហាង ឬម្ចាស់ផ្ទះ គួរតែដឹងថាខ្លួនត្រូវធ្វើអ្វីហើយនៅពេលការដ្ឋានមិនទាន់ទៅឆ្ងាយនៅឡើយនោះ៕

Continued from page 15

## Airport Bribes Continue to ...

**BY HUOT CHANPAV AND SIMON HENDERSON | AUGUST 5, 2015**

International visitors to Cambodia are still being asked to hand over small bribes upon entering the country, despite promises over the past few years to stamp out the practice, the head of a tourism working group said he told the government during his last meeting in the position.

Cambodia's airports and border checkpoints are notorious for the immigration officers who demand "tea money" from visitors. In 2013, a Chinese journalist penned a scathing article in the Global Times newspaper after officials at Siem Reap International Airport asked her to pay a bribe.

But the problem persists, according to Ho Vandy, outgoing co-chair of the Government-Private Sector Working Group on Tourism, who said he raised the issue at a meeting on Sunday, during which chef and hotelier LuuMeng was named as his replacement.

"This problem [still] happens at Phnom Penh International Airport and Siem Reap International Airport, and at the Poipet and Bavet international checkpoints, and the victims are mostly Chinese and Taiwanese tourists," he said.

"If our hospitality is bad, they will remember," he added. "It affects them psychologically. In return, this affects Cambodia's tourism industry in both private and state sectors."

Lieutenant General KeoVannthan, deputy director of the Interior Ministry's immigration department, denied that his officers took bribes.

**Ageless Divine Salon & Spa**

ហាងអ៊ុតសក់ ថែសម្ផស្សមុខ និងធ្វើក្រចក

450 Chelmsford Street.
Lowell, MA 01852

**978-364-1300**

តមកពីទំព័រទី ០៤

## និយាយពីអ្នកក្រ និងអ្នកមាន

នៅពេលយើងបើកប្រអប់សម្ងាត់នៅមើល? ១ឆ្នាំ=៣៦៥រៀល ១០ឆ្នាំ=៣.៦៥០ ២០ឆ្នាំ=៧.៥០០៛ ។ ...លុយចំនួននេះ គឺច្រើនគួរសម នាមុនឆ្នាំ១៩៧០អាចបញ្ជូនកូនទៅរៀនមហាវិទ្យាល័យបានដែរ។

ចុះបើយើងយកទ្រឹស្ដីនេះ មកប្រើនៅស.រ.អា. តើវាទៅជាយ៉ាងណា? ឧទាហរណ៍លើប្រាក់ចំណូលប្រចាំខែ:

១ខែសន្សំ=១០០ដុល្លា... ១ឆ្នាំសន្សំ=១.២០០ដូ ...១០ឆ្នាំសន្សំ=១២.០០០ដូ... ២០ឆ្នាំសន្សំ =២៤.០០០ដុល្លារ ។

**ពន្យល់ពីករណីនៅសហរដ្ឋអាមេរិក**

សេដ្ឋកិច្ចនៅស.រ.អា.នេះ អាចធានាការងារក្នុងប្រាក់ខែតិចបំផុត១.៥០០ដុល្លា ដោយស្របច្បាប់ចំនួន២០ឆ្នាំបាន។ ដូចដែលនិយាយពីភាគ១មុនអាយុ១៨ឆ្នាំ កូនមិនមានការទទួលខុសត្រូវក្នុងការរកប្រាក់ចំណូលទេ ដូច្នេះគឺជាភារកិច្ចម្ដាយឪពុកជាអ្នករកលុយនឹងត្រៀមលុយសម្រាប់បណ្ដុះបណ្ដាលកូនលុយដែលនៅក្នុងប្រអប់សម្ងាត់នោះជា"លុយងាប់"

**ទ្រឹស្ដីទី២-លុយរស់**

សន្សំ"លុយងាប់"ចំនួន២០ឆ្នាំ បានក្លាយទៅជាគុណវិបត្តិទៅហើយនាបច្ចុប្បន្នកាលនេះ ពីព្រោះលុយនោះអាចឋិតនៅកន្លែងធានាសុវត្ថិភាពដូចគ្នាតែជា"លុយរស់"អាចបង្កើតកូនបន្តទៀតឱ្យកាន់តែច្រើនឱ្យយើងបានយ៉ាងស្របច្បាប់ដែរ។ គឺជាលុយរក្សាជាសម្ងាត់នៅក្នុងធានាគារសុវត្ថិភាពមានការប្រាក់សមរមជាប្រចាំ




ធានាថា មិនឱ្យខាតដែលប្រាក់នោះមានគុណសម្បត្តិច្រើនជាងគ្រាន់តែសន្សំលុយឱ្យកូនតែប៉ុណ្ណោះទៀតផង។

ឧទាហរណ៍:

ធនាគារ"ក": លុយរស់ - កាប្រាក់ងាប់

សន្សំឆ្នាំទី១-១០.០០០៛ បានកាប្រាក់៨ភាគរយ=១០៨០០៛

សន្សំឆ្នាំទី២-១០.០០០៛ បានកាប្រាក់៨ភាគរយ=១១.៦០០៛

សន្សំឆ្នាំទី៣-១០.០០០៛ បានកាប្រាក់៨ភាគរយ=១២.៤០០៛

**តទៅលេខក្រោយ**

## AMERICAN MUFFLER & BRAKE

យានដ្ឋានខ្មែរជួសជុលរថយន្តទូទៅតម្លៃសមរម្យ



Known as A muffler man. Customize pipe, exhaust & welding. come to see us we can make the different.

Shock & Struts, Tune-up, Axle Trans, Timing Belt, Customized Pipe Exhaust Clutch, Water Pump, Starter and much more...

WE FIX-U $SAVE

1380 Park Ave.
Cranston, RI 02920
Cell: 203-522-2174
www. amufflerman.com

Monday-Saturday 8:00 am-7:00 pm Phone: 401-944-3390

Open Sunday 9:00 am-3:00 pm Fax: 401-944-3390

**Mony, Chay, Sokheang, Sokheng & Jimmy**

WE ARE AT FIVE LOCATIONS

| 1412 Park Ave. | 335 Whalley Ave. | 1355 South Main St. | 219N. Colony Rd. |
|---|---|---|---|
| Bridgeport, CT 06604 | New Haven, CT 06511 | Waterbury, CT 06706 | Wallingford, CT 06492 |
| (203) 333- 0355 | (203) 777- 9800 | (203) 757-7575 | (203) 284-0861 |

## LICO WIRELESS & GENERAL SERVICES

Cellphone & Computer Repair

**978-735-4100**

GoSmart Mobile * T-Mobile Prepaid * Simple Mobile
H20 Wireless * Black Wireless * Lyca Mobile
GSM Phone * All Prepaid Wireless * Pay All bills
Open: Mon-Sat, 10 - 7PM
336 Westford St. #1, Lowell, MA 01851

## រកអ្នកធ្វើការ -ជាងធ្វើក្រចកស្រី ឬប្រុស

ប្រាក់ខែជូនទៅតាមបទពិសោធន៍ពី $៥០០-$១.០០០ ក្នុង១អាទិត្យ
កន្លែងធ្វើការរវល់ច្រើន
Trenton, NJ ចម្ងាយ៤៥នាទី ពីហ្វីឡាដែលហ្វៀ
សម្រាប់អ្នកនៅឆ្ងាយមានកន្លែងឱ្យសំណាក់
ទូរស័ព្ទ : **609-227 1939**

## Help wanted – Nail Technician M or F

Salary base on experience $500-$1,000/week
Busy location, Trenton, NJ 45mn.from Philly
For long distance, Provided accommodation
Call **609-227 1939**

**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ
ចំណាយចំណាយត្រឹមតែ
**$50** ក្នុង១ខែ

***CALL:***
***978.677.7163***

*EMAIL: SOBENPIN@KHMERPOST.US*

## សន្សំលុយថ្លៃប្រើភ្លើង និងហ្គាស

Pay less for
Electric and Gaz bill
Only**8.50**cent/kwh
Just switch supplier to : Ambit
“no cost to switch”
“No hidden fees”
Call Kunnan
**(978)401 7806**
**or Alex (978)569 6034**



## CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

## ខូម័រ សិប្បកម្មឆ្លាក់សំណាកក្រានីត
## COLMER MONUMENT WORKS

Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
**(978) 452-7821**




- Granite Memorials — ផ្ទាំងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers — ផ្ទាំងផ្តេកមានឆ្លាក់សិទ្ធិលេខថ្មក្រានីត
- Cemetery Lettering in Khmer — មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
*Honor. Dignity. Respect for All*



# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

## តុលាការខ្មែរស្តាប់បង្គាប់លោកនាយករដ្ឋមន្ត្រី

ភ័ស្តុតាងដែលបញ្ជាក់ថា តុលាការខ្មែរស្តាប់បង្គាប់លោកនាយករដ្ឋមន្ត្រីមានពីរៈ ១-បន្ទាប់ពីតុលាការចាប់សកម្មជនគណបក្សសង្គ្រោះជាតិ១១នាក់ដាក់ក្នុងពន្ធនាគារព្រៃសមក លោកនាយករដ្ឋមន្ត្រី ក្នុងពិធីសម្ពោធស្ពានមិត្តភាពកម្ពុជាចិននៅតាខ្មៅខេត្តកណ្តាល កាលថ្ងៃ៣សីហា២០១៥ បានបញ្ជាឲ្យចាប់បាតុករដាក់ពន្ធនាគារជាបន្តទៀត។ បញ្ជាបានតែមួយថ្ងៃ តុលាការសហការជាមួយសន្តិសុខបានតាមចាប់បាតុករ៥នាក់ទៀត ដូច្នេះ គេមើលឃើញថា ឲ្យតែនាយករដ្ឋមន្ត្រីបញ្ជា សន្តិសុខនិងតុលាការធ្វើតាមភ្លាម។

២-លោកឈូកបណ្ឌិតអតីតៈអភិបាលក្រុងស្វាយរៀងបានបាញ់ឲ្យកម្មការិនី៣នាក់ត្រូវរបួសធ្ងន់ កាលពីឆ្នាំ២០១៣ តុលាការសាលាដំបូងស្វាយរៀងបានកាត់ឲ្យជាប់ទោស ១៨ខែ។ តែក្នុងរយៈកាលជិត៣ឆ្នាំ គេពុំឃើញលោកឈូកបណ្ឌិតជាប់ក្នុងពន្ធនាគារតាមការសម្រេចនោះឡើយ។ លោកនាយករដ្ឋមន្ត្រីបញ្ជាថា ត្រូវតែតាមចាប់លោកឈូកបណ្ឌិតមកធ្វើទោស បញ្ជាបានតែ៥ថ្ងៃ ស្រាប់តែលោកឈូកបណ្ឌិតត្រូវចាប់បាន ខ្លះថាចូលមកទទួលសារភាព។ដូច្នេះបញ្ជាក់ថា តុលាការស្តាប់បង្គាប់លោកនាយករដ្ឋមន្ត្រី។

ទីស្តីការគណៈរដ្ឋមន្ត្រីបានកាត់តរូបភាពវីដេអូនៅកន្លែងកើតហេតុ ជាធម្មតាការចង់ឈ្នះចាញ់គ្នា ត្រូវទុកកន្លែងណាដែលមានប្រៀបដល់គូម្ខាងទៀត ហើយត្រូវកាត់ចោលត្រង់កន្លែងមិនល្អ ដូចសន្តិសុខវាយនិងបាញ់ពលរដ្ឋ។ តើគណបក្សសង្គ្រោះជាតិមានវីដេអូបង្ហាញទេ? ឫធ្វេសប្រហែសមិនបានថត សុំខ្ចីអ្នកបានថតយកមកប្រៀបធៀបគ្នារកការពិត។ គណបក្សសង្គ្រោះជាតិ បានប្រើវប្បធម៌សន្ទនាសុំដោះលែងសកម្មជនទាំងអស់ដែលបានចាប់ តែអ្នកនាំពាក្យ ជាពិសេស លោកសុខឥសានជាជើងខ្លាំងម្នាក់ពោលថា គេមិនអាចយកការសន្ទនាមកលាយឡំជាមួយតុលាការផ្លូវច្បាប់បានឡើយ។ ចុះបើតុលាការមិនឯករាជ្យដូចពោលមកនេះ តើលោកសុខឥសានគិតយ៉ាងណាដែរ?

វត្តខ្មែរកាណាដា,ថ្ងៃ១១សីហា២០១៥;www.hoksavann.org;savannhok@yahoo.com

---

**មណ្ឌលពុទ្ធសាសនាតំបន់ញូអ៊ិងឡិន**

**THE BUDDHIST CENTER OF NEW ENGLAND. INC**

252 Public Street, Providence, RI 02905

Telephone (401) 454-4633



# ព្រះរាជពិធីបុណ្យឧទ្ទិសមហាកុសល ថ្វាយសម្តេច ជោតញ្ញាណោ ជួន ណាត និងសម្តេច ឃោសានន្ទ ហ៊ិ យ៉ាវ ព្រមទាំង សម្តេចសង្ឃជាន់មុនៗ



ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំ ជាគណៈកម្មការ អាចារ្យ និងពុទ្ធបរិស័ទ ចំណុះជើង វត្ត **មណ្ឌលពុទ្ធសាសនា** ទីក្រុងប្រូវិដិន្ស រដ្ឋរ៉ូដអាយឡិន្ត មានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាបានមូលមតិគ្នាជាឯកច្ឆ័ន្ទផ្តើម ធ្វើព្រះរាជពិធីបុណ្យថ្វាយប្រគេនសម្តេចព្រះសង្ឃរាជ(ជោតញ្ញាណោ)**ជួន ណាត** និង**សម្តេចមហាឃោសនន្ទ** ព្រមទាំងសម្តេចសង្ឃគ្រប់ជំនាន់ ដែលក្នុងមួយជីវិតសម្តេចបានបូជាព្រះកាយដើម្បីបម្រើព្រះពុទ្ធសាសនា និងបន្សល់ស្នាមព្រះហស្តជាច្រើន មានអក្សរសាស្ត្រខ្មែរទុក អោយកុលបុត្រខ្មែរ បានសិក្សារៀនសូត្រ។

អាស្រ័យហេតុនេះ យើងខ្ញុំព្រះករុណា អាត្មាភាព សូមគោរពនិមន្តព្រះតេជគុណ និងចំរើនពរអញ្ជើញ លោក លោកស្រី លោកតា លោកយាយ ញាតិមិត្តជិតឆ្ងាយទាំងអស់ មេត្តាអញ្ជើញ ចូលរួមចាប់មគ្គផល និងអនុមោទនាយក ចំណែកបុណ្យកុសលតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗ ខ្លួនកុំបីឃ្លៀងឃ្លាតឡើយ ។

**កម្មវិធីបុណ្យ**

**SATURDAY- SUNDAY, AUGUST 29 -30, 2015**

☞ថ្ងៃសៅរ៍១៥កើតខែស្រាពណ៍ ព.ស២៥៥៩ ត្រូវនិងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៥

☞វេលាម៉ោង៦:៣០ល្ងាច ជួបជុំពុទ្ធបរិស័ទ និងភ្ញៀវកិត្តិយសជិតឆ្ងាយនៅវត្តមណ្ឌលពុទ្ធសាសនា រួចធ្វើកិច្ចនមស្ការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃចំរើនព្រះបរិត្ត និងសម្តែងធម៌ទេសនា។

☞លុះថ្ងៃអាទិត្យ ខែឆ្នាំដដែល ម៉ោង៩:៣០ ព្រឹក ជួបជុំពុទ្ធបរិស័ទ នមស្ការព្រះរតនត្រ័យ សមាទានសីល វេរភត្ត ប្រគេនព្រះសង្ឃ ឧទ្ទិសព្រះរាជកុសលថ្វាយប្រគេន សម្តេចគ្រប់ជំនាន់ និងសំដែងធម្មទេសនា ជាកិច្ចបញ្ចប់កម្មវិធីបុណ្យ។

**ទីកន្លែង៖ វត្តមណ្ឌលពុទ្ធសាសនា BUDDHIST CENTER OF NEW ENGLAND, INC**

252 Public Street, Providence, RI 02905. Tel: 401-454-4633

**អ្នកផ្តើមបុណ្យ**

-ព្រះគ្រូចៅអធិការ វត្តមណ្ឌលពុទ្ធសាសនា (ឃោសកោវិទសុទ្ធិ) យៀង សុចិត្រា និងព្រះសង្ឃគ្រប់ព្រះអង្គ

-គណៈកម្មការ អាចារ្យ និង ពុទ្ធបរិស័ទចំណុះជើងវត្ត


# ហ្វេយ៍មីកខេប ផ្ទះសម្រាប់ពិធីបុណ្យសព

# Fay McCabe Funeral Home

105 Moore Street. Lowell, MA 01852

**978-459-9222**



**បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ**

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបចំរោងមុនកម្មវិធីបុណ្យសព

Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក ចន្លោះផ្លូវ Gorham St. & Lawrence St.

*លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។*

www.faymccabe.com

**មានបុគ្គលិកនិយាយភាសាខ្មែរ**

តមកទំព័រទី ១៩

# សំណូកនៅអាកាសយានដ្ឋាន...

**ដោយ ហួត ចាន់ប៉ារ៉ និង សៃម៉ុន ហេនជីរសិន** | **August 5, 2015**

ប្រធានក្រុមការងារទេសចរណ៍បាននិយាយថា លោកបានប្រាប់រដ្ឋាភិបាលអំឡុងកិច្ចប្រជុំចុងក្រោយរបស់លោកក្នុងតំណែងថា ភ្ញៀវទេសចរអន្តរជាតិដែលធ្វើដំណើរមកប្រទេសកម្ពុជានៅតែត្រូវគេទារសំណូកបន្តិចបន្តួចនៅពេលចូលប្រទេសនេះ បើទោះជាមានការសន្យាកាលពីពីរបីឆ្នាំមុន ថានឹងបំបាត់លែងឱ្យមានការធ្វើដូច្នេះក៏ដោយ ។

អាកាសយានដ្ឋាននិងច្រកព្រំដែនរបស់ប្រទេសកម្ពុជាមានឈ្មោះអាក្រក់ ព្រោះមន្ត្រីដែលបានទាមទារ "លុយទឹកតែ" ពីភ្ញៀវ។ ក្នុងឆ្នាំ ២០១៣ អ្នកកាសែតចិនម្នាក់បានសរសេរអត្ថបទរិះគន់យ៉ាងខ្លាំងក្នុងកាសែត គ្លូបល ថាមស៍ បន្ទាប់ពីក្រុមមន្ត្រីនៅឯអាកាសយានដ្ឋានអន្តរជាតិបានសុំឱ្យនាងបង់សំណូក។

យោងតាមលោក ហូ វណ្ណី សហប្រធានជិតផុតអាណត្តិនៃក្រុមការងារវិស័យរដ្ឋាភិបាល-ឯកជនផ្នែកទេសចរណ៍បាននិយាយថា លោកបានលើកបញ្ហានេះនៅកិច្ចប្រជុំកាលពីថ្ងៃអាទិត្យដែលនៅពេលនោះ ចុងភៅធំ និងជាម្ចាស់សណ្ឋាគារ លោក លូ ម៉េង ត្រូវបានតែងតាំងជាអ្នកកាន់ការជំនួសលោកបានឱ្យដឹងថា បញ្ហានេះនៅតែបន្តមាន ។

លោកបាននិយាយថា "បញ្ហានេះឱ្យនៅតែ "កើតឡើងនៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងនៅតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត និងបាវិត ហើយជនរងគ្រោះភាគច្រើនជាទេសចរចិន និងតៃវ៉ាន់" ។

លោកបានបន្ថែមថា "ប្រសិនបើការទទួល

តទៅទំព័រទី ២៣

រាក់ទាក់របស់យើងមិនល្អ ពួកគេនឹងចងចាំ។ វាប៉ះពាល់ផ្លូវចិត្តពួកគេ។ ជាផលបកវិញ វាប៉ះពាល់ឧស្សាហកម្មទេសចរណ៍របស់ប្រទេសកម្ពុជាទាំងវិស័យឯកជនទាំងវិស័យរដ្ឋ" ។

ឧត្តមសេនីយ៍ឯក កែវ វ៉ាន់ថន អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃបានបដិសេធថាមន្ត្រីរបស់លោកមិនបានទទួលសំណូកទេ ។

លោកបាននិយាយថា "ខ្ញុំមិនដែលបានឮរឿងនេះទេ។ យើងបានដាក់សញ្ញានៅអាកាសយានដ្ឋានឱ្យណែនាំអ្នកធ្វើដំណើរ "អំពីការទារប្រាក់សំណូក"។ លោកបានបន្ថែមថា ប៉ូលិសដែលគេទាន់ពេលទារប្រាក់ភ្ញៀវអាចត្រូវគេទម្លាក់សក្តិ ឬបណ្តេញចេញពីការងារ ។

នៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញកាលពីថ្ងៃអង្គារអ្នកដំណើរ១២នាក់ដែលសម្ភាសពេលមកដល់តាមជើងហោះហើរពីប្រទេសសិង្ហបុរីបាននិយាយថា ពួកគេបានឆ្លងកាត់តាមរយៈអន្តោប្រវេសន៍ដោយគ្មានការទារសំណូកទេ។

Continued from page 12

# Military Seeks More Money...

the government that was created through elections," he added.

CheaVannath, a political analyst and former president of the Center for Social Development, said the private sector funding of the military would undoubtedly lead to favoritism.

"For sure it will," she said. "Like in the Khmer saying, you do not bite the hand that feeds you."

(Additional reporting by Chris Mueller)



# វិធីព្យាបាលជំងឺគ្រោះតម្រងនោមឱ្យជាសះស្បើយ

ផ្លែល្ហុងខ្ចីត្រូវបានគេទទួលស្គាល់ថា ជាឱសថបុរាណអាចព្យាបាលជំងឺគ្រោះក្នុងតម្រងនោមបានយ៉ាងមានប្រសិទ្ធិភាព។ គ្រោះក្នុងតម្រងនោមកើតឡើងនៅពេលមានការប្រមូលផ្តុំនូវសារធាតុខនិជជាច្រើនដូចជា: កាល់ស្យូម្ម, អុកសាឡាត, អំបិលផូស្វាតនៅក្នុងទឹកនោមមានការកើនឡើង និងកាកសំណល់ទាំងអស់នេះបានក្លាយជាគ្រោះក្នុងតម្រងនោម។ ជាធម្មតាគ្រោះក្នុងតម្រងនោមមានរាងមូលរលោង ។ ប្រសិនបើគ្រោះក្នុងតម្រងនោមមានរាងមូលជាធម្មតាមិនបណ្តាលឱ្យអ្នកជំងឺមានការឈឺចាប់ឡើយ ប៉ុន្តែប្រសិនបើគ្រោះមានរាងស្រួចចុងតម្រងនោមនឹងមានការឈឺចាប់យ៉ាងខ្លាំង។ ប្រសិនបើមិនព្យាបាលវាឱ្យបានទាន់ពេលទេ គ្រោះក្នុងតម្រងនោមអាចបង្កឱ្យជីវិតជួបនឹងភាពស្មុគស្មាញធ្ងន់ធ្ងរ។ មានវិធីសាស្ត្រជាច្រើនអាចព្យាបាលជំងឺគ្រោះក្នុងតម្រងនោមបាន ដូចជា ការវះកាត់ដើម្បីយកគ្រោះចេញ, លេបថ្នាំដើម្បីរំលាយគ្រោះ... ប៉ុន្តែអ្នកកើតជំងឺគ្រោះក្នុងតម្រងនោមជាង ៦០% កើតជំងឺនេះម្តងទៀត។ ហេតុផលមួយដោយសារគ្រោះក្នុងតម្រងនោមត្រូវបានកម្ចាត់ចោលប៉ុន្តែការកើតឡើងនៃគ្រោះនៅតែមាន។ ប្រសិនបើមិនរំលាយអស់ទេ ដុំគ្រួសល្អិតដែលនៅសល់



នឹងបណ្តាលឱ្យមានការឈឺចាប់, អស់កម្លាំង និងធ្វើឱ្យអ្នកជំងឺត្រូវចំណាយប្រាក់អស់ច្រើន។ ជានិច្ចកាលគ្រោះក្នុងតម្រងនោមត្រូវបានព្យាបាលដោយប្រើឱសថបុរាណធម្មជាតិ។ ឱសថបុរាណនេះអាចកម្ចាត់ដុំគ្រោះយ៉ាងមានប្រសិទ្ធិភាព ហើយទីបំផុតគ្រោះត្រូវបានកម្ចាត់ចេញតាមរយៈទឹកនោម, ដោយគ្មានភាពឈឺចាប់ ហើយជាពិសេសមិនចាំបាច់ត្រូវវះកាត់។ ជាយូរលង់ណាស់មកហើយ ឱសថបុរាណផ្លែល្ហុងខ្ចីត្រូវបានគេទទួលស្គាល់ថា អាចជួយព្យាបាលជំងឺគ្រោះក្នុងតម្រងនោម។ ឱសថចុងក្រោយសាមញ្ញៗប៉ុន្តែមានប្រសិទ្ធិភាពខ្ពស់ដែលអ្នករាល់គ្នាអាចធ្វើបាន។ វិធីសាស្ត្រដើម្បីព្យាបាលជំងឺគ្រោះក្នុងតម្រងនោមដោយប្រើផ្លែល្ហុង: ប្រើកាំបិតពុះល្ហុង, យកគ្រាប់ចេញ, ទុកសំបកល្ហុង។ រួចដាក់អំបិលបន្តិចចូលក្នុងល្ហុង ហើយដាក់ចំហុយរហូតដល់ផុយ,ទុកឱ្យត្រជាក់រួចទទួលទានទាំងសំបក។ ទទួលទាន១ថ្ងៃម្តង រយៈពេល ៧ ថ្ងៃ គ្រោះក្នុងតម្រងនោមនឹងបាត់អស់។ កំណត់ចំណាំនៃការប្រើផ្លែល្ហុងដើម្បីព្យាបាលជំងឺគ្រោះក្នុងតម្រងនោម: មុននឹងព្យាបាលដោយប្រើឱសថធម្មជាតិនេះ គួរតែទៅមណ្ឌលសុខភាពដើម្បីពិនិត្យមើលថា តើគ្រោះក្នុងតម្រងនោមមានទំហំប៉ុណ្ណា ។ ក្រោយពេលប្រើឱសថនេះរួច គួរតែទៅពិនិត្យម្តងទៀតដើម្បីដឹងពីប្រសិទ្ធិភាពរបស់ឱសថ, ថាតើគ្រោះក្នុងតម្រងនោមបាត់អស់ ឬនៅ? ប្រសិនបើគ្រោះល្អិតៗក្នុងតម្រងនោមមិនទាន់អស់ទេ អ្នកត្រូវបន្តប្រើវិធីនេះអាចដល់ទៅ១ ឬ ២ខែ។

លើសពីនេះទៀត ក្រៅពីឱសថអ្នកជំងឺគួរតែទទួលទានបន្លែបៃតងឱ្យបានច្រើន, ផ្លែឈើ, ទឹកឱ្យបានគ្រប់គ្រាន់ដើម្បីព្យាបាលជំងឺគ្រោះក្នុងតម្រងនោមនេះ ៕

តមកពីទំព័រទី ០៣ ការិយាល័យ...

នៅឡូវែលមានកន្លែងហូប "អាយស្រ្គីម" ហើយនឹងភោជនីយដ្ឋាននៅ Heritage Farm រាល់យប់ថ្ងៃចន្ទមានភ្លេងឱ្យស្តាប់នៅខាងក្រៅទៀត។ នៅ Sampas Pavillion ឡូវែលដដែលមានលេងភ្លេងនៅម៉ោង ៧យប់។ មុនពេលប្តើមលេងភ្លេងនៅម៉ោង៦ មានបង្ហាញរថយន្ត The Classic Car Show ដែលគួរតែនាំគ្រួសារមកមើលដេលមិនអស់លុយ ។

**កម្មវិធីខែសីហា២០១៥មាន:**

- The Tony O Band- Monday August 10, 2015
- Classic Trax- Monday August 17, 2015
- Sturdy Moss- Monday August 24, 2015
- FREEVOLT- Monday August 31, 2015

There are also a number of local musicians performing at NARA Park at 25 Ledge Rock Way in Acton. Bring the family and enjoy a fun evening under the stars. Concert is from 6:30-8pm

- Dell Smart & Exit-August 13

យើងសង្ឃឹមផងដែរថា លោកអ្នកនឹងមកមើលបុណ្យអុំទូកនៅ Sampas Pavilion in Lowell នាថ្ងៃសៅរ៍ ១៩សីហា២០១៥។ បុណ្យនេះឧទ្ទិសដល់ការថែរក្សានឹងការចូលរួមកេរដំណែលវប្បធម៌សហគមន៍អាស៊ីអគ្នេយ៍ ។ សូមអញ្ជើញមកទទួលការប្រោះព្រំនៃទឹកទស្សនាប្រណាំងទូកបែបបូរាណសាកភ្លក់ម្ហូបចំណីដែលដាក់លក់តាមតូប ហើយនឹងរីករាយនឹងស្នាដៃផ្សេងៗយ៉ាងច្រើនទៀត ៕


AccuCare
Home Care Agency
Group Adults Foster Care Program

## កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើងតាមរយ:ការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណ:ដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ
  អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

ផលប្រយោជន៍ទទួលបាន :

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីឃើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

*To be eligibled for GAFC you must:*

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

*Benefits you will get:*

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed
for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវ:
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# តមកពីទំព័រទី ០១ សម រង្ស៊ីថា សកម្មជនជាប់ទោស...

រក្សាអនាធិបតេយ្យមួយចំនួនអនុញ្ញាតិឱ្យសមាជិកថ្នាក់ក្រោមជិះជាន់អ្នកឯទៀតបន្តរគ្នា ដូច្នេះគឺពុំមែនការចាប់ចងមន្ត្រី ឬឧកញ៉ា មេប៉ូលីស ឬទាហ៊ានខ្លះៗនោះជាចំណុចរសើបនោះទេ វាគ្រាន់តែធ្វើឱ្យល្អមើលតែប៉ុណ្ណោះ។ បើអីចឹងនៅសល់ចំណុចរសើបគឺបញ្ហាទាក់ទងនឹងប្រទេសវៀតណាមតែមួយប៉ុណ្ណោះ ដែលស្លាក់បំពង់ក ហ៊ុន សែន មិនអាចឱ្យទាញថយក្រោយមកបំភ្លេចចោលវិញបានទេ។

វប្បធមិសន្ទនា បានធ្វើឱ្យ ហ៊ុន សែន ភ្លាត់ស្នៀត២ចំណុចធំៗ ១ ការកែរច្បាប់បោះឆ្នោតនឹងប្តូរគ.ជ.ប.អាចឱ្យធ្វើទៅបាន ២ ការពិតនៃការប្រើផែនទីដើម្បីបោះបង្គោលព្រំដែនខ្មែរវៀតណាមកំពុងតែត្រូវសើរើ។

ភ្លាត់ស្នៀតទី១ គ.ជ.ប.ថ្មីកំពុងដំណើរកាណ៏ក្នុងជោគជ័យទៅរកការផ្លាស់ប្តូររបបគ្រប់គ្រងរង់ចាំតែអនុវត្តន៏នៅឱកាសបោះឆ្នោតដំបូងឆ្នាំ២០១៧នឹងមកដល់ប្រជាពលរដ្ឋបានបង្ហាញរួចជាស្រេចថា ប្តូរឱក្នុងដំណាក់ការទី១ ប្តូរអំណាចថ្នាក់មូលដ្ឋាន ហើយនៅឱកាសបោះឆ្នោតទី២ ឆ្នាំ២០១៨ នឹងមានការប្តូរអំណាចថ្នាក់ដឹកនាំ។ នេះដោយសារសមាសភាពគ.ជ.ប. ដែលពីដើមជាសមាជិកគណបក្សប្រជាជន១០០ភាគរយ អីឡូវសមាជិកមកពីគណបក្សប្រជាជនមានតិចជាង៥០ភាគរយ ដែលគេអាចទាយបានថា ការបោះឆ្នោតទៅថ្ងៃមុខនឹងបានលទ្ធផលឆ្លុះបញ្ចាំងពីឆន្ទម្ចាស់ឆ្នោតបានប្រសើរជាងមុនៗ។ ហ៊ុន សែន បានបង្ហាញនូវសញ្ញាជាច្រើន ថាមានការព្រួយបារម្ភពីប្រជាប្រិយភាពរបស់គណបក្សខឡួន ហើយខំធ្វើសកម្មភាពទប់ស្កាត់រាល់ពេលដែលអាចធ្វើបាន។

ភ្លាត់ស្នៀតទី២ ផ្តើមដោយ សម រង្ស៊ី ដកបង្គោលតម្រុយព្រំដែនខ្មែរវៀតណាមប្រជា-ពលរដ្ឋបះបោរទៅទល់ដែនទៅការពារព្រំដែនកម្ពុជាជំនួសកងទ័ព រហូតដល់មានការបណ្តេញយួនខុសច្បាប់ចេញពីប្រទេសខ្មែរបានខ្លះ...មានការសរសេរលិខិតការទូតព្រមានវៀតណាម...មានការស្នើឱ្យផ្ទៀងផ្ទាត់ផែនទីដែលត្រឹមត្រូវដើម្បីបោះបង្គោលព្រំដែន...មានការទាក់ទងជាមួយចិន ដើម្បីទប់ទល់នឹងវៀតណាម...រឿងនេះបានរុលទៅមុខនឹងបំបាក់មុខមាត់វៀតណាមជាឪអ្នកមានគុណឱលើថ្នាក់ដឹកនាំខ្មែរខាងគណបក្សប្រជាជនច្រើនឆ្នាំមកហើយ យ៉ាងសម្បើម។ នៅលើចំណុចតែមួយនេះ រឿងព្រំប្រទល់ដែនមិនត្រឹមតែធ្វើឱ្យប្រជាពលរដ្ឋខ្មែររាប់រយពាន់ក្រោកឡើងបង្ហាញភស្តុតាង ថាយួនយកដីកេរ


លោក សម រង្ស៊ី និងលោក ហ៊ុន សែន

របស់ខ្លួននេះរាប់ទាំងដីរបស់លោក ហេង សំរិន ប្រធានរដ្ឋសភាផងនោះទេ រដ្ឋបាល ហ៊ុន សែន បានដកថយច្រើនជំហ៊ានទៅរកកិច្ចព្រមព្រៀងខ្មែរវៀតណាម ហើយលើកយកផែនទីត្រឹមត្រូវនៅអង្គការសហប្រជាជាតិអាចនឹងមកប្រើសម្រាប់កំណត់ព្រំដែនវិញ... មកដល់ត្រង់នេះ ធ្វើឱ្យគណបក្សសង្គ្រោះជាតិមានប្រៀបលើទឹកចិត្តប្រជាពលរដ្ឋថា ជាអ្នកការពារនឹងរកយុត្តិធមិជូនជាតិជាងគណបក្សប្រជាជន...ហើយនឹងដក់ជាប់ក្នុងចិត្តរហូតដល់ថ្ងៃបោះឆ្នោតដែលពេលនោះ គណបក្សប្រជាជនមិនអាចទុកចិត្តគ.ជ.ប.ថាបំរើខ្លួនបានដូចពេលបោះឆ្នោតមុនៗទៀតទេ។

តើការត្រៀមទប់ទល់លទ្ធផលបោះឆ្នោតយ៉ាងតឹងតែងរបស់ ហ៊ុន សែន អាចនឹងក្លាយជាសង្គ្រាមស៊ីវិលបានដែរឬទេ? លទ្ធផលនៃវប្បធមិសន្ទនាបានហុចផ្លែផ្កាមកច្រើនហើយ ដែលបានធ្វើឱ្យប្រជាពលរដ្ឋមានការកក់ក្តៅមិននឹកទៅរកបដិវត្តន៏ដូចដែល ទា បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិយល់នោះទៀតទេ...នេះគឺជាការយល់ច្រឡំថ្មីរបស់ក្រុមចរន្តតឹងនៃ ហ៊ុន សែន មួយទៀតហើយ។ ការតែងតាំងរបស់ព្រះមហាក្សត្រឱ្យគោរម្យងារជាសម្តេចក្រឡាហោមទៅ ស ខេង នឹងសម្តេចសេនាភក្តីទៅ សាយ ឈុំ មិនមែនជាឋានន្តរសក្តិលំអទីក្រុងតែប៉ុណ្ណោះទេ វានឹងក្លាយទៅជាចរន្តទប់ទល់វិបត្តផ្ទៃក្នុងគណបក្សប្រជាជនដ៏មានកម្លាំង ដូចដែលធ្លាប់មាន កាលពីជំនាន់ ជា ស៊ីម នៅរស់ដូចគ្នាដែរ ហើយចរន្តក្រោយនេះ នឹងជំនួសចរន្ត ហ៊ុន សែន នៅពេលណាមួយដែលរលំមិនឱ្យគណបក្សប្រជាជនបាក់មុខនឹងរលាយដូចជាក្រុមខ្មែរក្រហមនោះទេ។ បើចន្ទតឹងនេះធ្លាក់ឆ្នោតនៅឆ្នាំ២០១៨ ក៏គណបក្សប្រជាជននៅតែមានវត្តមាននៅសភាតទៅទៀតដែរ... ពីព្រោះសង្គ្រាមនឹងមិនអាចធ្វើបាន ឬការបង្ក្រាបក៏ជាអាវុធមុខ២ បើហ៊ានកាប់គេអ្នកឯងនឹងចាញ់ឆ្នោតជាមិនខាន។

ដូច្នេះយោបល់ដែលថាគណបក្សសង្គ្រោះ


សម្តេច ស ខេង



លោក មាជ សុវណ្ណារ៉ា

ជាតិចាក់ចំចំណុចរសើបនៃព្រំប្រទល់ដែនខ្មែរវៀតណាម ហើយនោះក៏ដោយក៏អាចនឹងចាញ់ទៅវិញបានដែរ ដោយសារគណបក្សប្រជាជន ក៏គេប្រឹងរៀបទប់ទល់ណាស់ដែរ ដោយប្រើយុទ្ធសាស្ត្រគម្រាមនឹងបំបែកមិនចេះចប់នោះ ។ គណបក្ស៤ បានកើតរួចហើយ គឺ១.គណបក្សហ៊្វុនស៊ិនប៉ិចរបស់ទ្រង់ រណឫទ្ធិ ២.គណបក្សអំណាចពលរដ្ឋរបស់ សួន សេរីរដ្ឋា ៣.គណបក្សសំបុក្រឃ្មុំ របស់ ម៉ម សូណន់ដូ ៤.គណបក្សប្រជាធិបតេយ្យមូលដ្ឋានរបស់ យេង វីរ ឬ គឹម ឡី... គណបក្សទាំងនោះនឹងទៅបំបែកសន្លឹកឆ្នោតគណបក្សសង្គ្រោះជាតិដោយស្វ័យប្រវត្តិមិនទាន់ដឹងថា តិចឬច្រើនប៉ុណ្ណានៅឡើយទេ នេះអាស្រ័យតែគណបក្សសង្គ្រោះជាតិតែប៉ុណ្ណោះ ពីព្រោះម្ចាស់ឆ្នោតបានសម្រេចចិត្តរួចហើយ។

អ្វីទៅដែលនឹងរក្សាកម្លាំងគណបក្សសង្គ្រោះជាតិ បានដ៏រាបណាគណបក្សសង្គ្រោះជាតិនៅមានលំនឹងរឹងមាំក្នុងការរួបរួមគ្នាបំរើជាតិជាធ្លុងមួយដដែលប្រជាពលរដ្ឋច្បាស់ជានៅចងចាំថាគណបក្សណាមួយដែលនៅកាពារទឹកដីយ៉ាងក្រាញននាលជាមួយប្រជាពលរដ្ឋ...ហើយគេនឹងបោះឆ្នោតឱ្យ...ពេលនោះគណបក្សដែលកើតដោយចៃដន្តទាំង៤ នឹងមិនមានទម្ងន់អ្វីសម្រាប់ឱ្យប្រជាពលរដ្ឋផ្លាស់ប្តូរចិត្តទៅរកខ្លួននោះទេ...។ តែបើប្រេះស្រាមបង្ហាញការបែកបាក់ផ្ទៃក្នុងទៅវិញ គណបក្សសង្គ្រោះជាតិនឹងឱ្យដៃចែកសន្លឹកឆ្នោតឱ្យទៅគណបក្សតូចៗដោយខ្លួនឯង ចំណែកអ្នកឈ្នះ គឺគណបក្សប្រជាជនរបស់ ហ៊ុន សែន ឯណោះទេ ដែលជាអ្នកឈ្នះ... រីឯគម្រោងស្នេហាជាតិការពារផែនដី ក៏ត្រូវយួនរក្សាយកបានជាស្ថាពរទៅដែរ នេះបើតាមខ្ញុំយល់ពីប្រយោគ សម រង្ស៊ី ៕






# ទូលព្រះបង្គំមិនហ៊ានរាយការណ៍ទេ ទាន ! (តពីភាគ៤)

**ដោយ : បញ្ញ សិលា** **តពីលេខមុន**



ហេតុនេះយើងគ្មានទទួលខុសត្រូវអ្វីទាំងអស់ ចូរអ្នករាល់គ្នាចុះទៅឋានកណ្តាលវិញសិនទៀបចាំព្រះសក្កទេវរាជត្រូវការកោះហៅចាំយើងឱ្យនាយសារថីទៅនាំខ្លួនចូលមកគាល់ព្រះអង្គ...”។ ស្របគ្នាពេលនោះអ្នកទីពីរមានអាការៈភ័យញ័រចំប្រប់ក្រាបវាន់ទារសុំថ្វាយយោបល់ ។ ទេពអគ្គលេខាសួរដំណើរដើមទងជននេះក៏បានដឹងថាគេជាទេពតាម្ចាស់ទឹកម្ចាស់ ទន្លេ ព្រែក បឹងបួរ នឹងសមុទ្រនៃនគរគោកធ្លោក ហើយមិនព្រមត្រឡប់ទៅវិញកើតទេមុននឹងបានទេពអគ្គលេខាសន្យាជួយស្រោចស្រង់ទោសរបស់ខ្លួនចំពោះសក្កទេវរាជ។ មិនទាន់បានទូលថ្វាយទេពអគ្គលេខាថា ម៉េចនៅឡើយផងស្រាប់តែមានអតិថិជនមួយក្រុមទៀតដង្ហែគ្នាចូលមកដល់ព្រមជាមួយគ្នាតែម្តង។ ទេពអគ្គលេខាហាក់ឆ្ងល់ក្នុងដួងហឫទ័យថា ពួកនេះវាចង់បបួលគ្នាបះបោរផ្តួលរំលំស្ថានទេវលោកហើយទេដឹងសហទេពកញ្ញាឡើងស្លាំងព្រះភ័កឈរនៅស្ងៀមមិនហ៊ានហាព្រះឱសចេញស្តីដល់មួយម៉ាត់ឡើយ ភាពឆ្ទះឆ្មើមរបស់ព្រះនាងរួញបាត់អស់ទៅណារលីងគ្មានសល់ ។ ឃើញអតិថិជនទាំងអស់ដែលព្រះនាងបានទារយកសេវាប្រចាំទិវាលើកគ្នាមកព្រមគ្នាយ៉ាងនេះព្រះនាងភ័យខ្លួនខ្លាចព្រះសក្កទេវរាជជ្រាបពីអំពើប្រមូលមាសពេជ្ជកែវកងពីអ្នកទាំងនោះ ព្រះនាងមុខជាត្រូវទទួលទោសឱ្យទៅចាប់កំណើតនៅស្ថានកណ្តាលមិនអាចគេចផុតបានឡើយ...។ ទោះបីទេពអគ្គលេខាបានស្គាល់អតិថិជនទាំងអស់នោះរួចស្រេចអស់ទៅហើយ ព្រោះម្នាក់ៗសុទ្ធតែបានទៅគាល់ព្រះអង្គម្តងរួចទៅហើយជាមួយនឹងដង្វាយផ្សេងៗពេលដែលពួកគេមកពីផែនដីសុវណ្ណភូមិដល់ស្ថានទេវលោកភ្លាម ។ តែធ្វើហាក់មិនស្គាល់មិនដឹងមិនមានទំនាក់ទំនងអ្វីនឹងគ្នាទាល់តែសោះទេពអគ្គលេខាសួរដោយសម្លេងសំឡុតគំរាមធ្វើឱ្យអ្នកចង់មកបង្ករឿងជាមួយព្រះអង្គចុះញ៉ូមបាក់បបខ្លួបខ្លាចមិនហ៊ានហើបមាត់ៈ “មើល! អ្នកទាំងអស់គ្នាជាអ្នកណា? ម៉េចក៏ហ៊ានធ្លើមធំ ចូលមកទីនេះគ្មានការអនុញ្ញាតយ៉ាងនេះ? អ្នកទាំងអស់គ្នាដឹងថាមានកម្រិតទម្ងន់ទោសដល់ថ្នាក់ណាទេ? អ្នកទាំងអស់គ្នាចង់ធ្វើអី? ម៉េចអ្នករាល់គ្នាមិនចាំយើងឱ្យកោះហៅម្នាក់ម្តងៗអ្នកទាំងអស់គ្នាចង់យកច្បាប់ពាលាអាវ៉ាសែនៅឯផែនដីមកអនុវត្តស្រេចតែក្បាលវ៉ាល់អ្នកឯងរាល់គ្នាមែនទេ អាណាមួយជាក្បាលម៉ាស៊ីនដឹកនាំឱ្យធ្វើយ៉ាងនេះ ចំជាធ្លើមធំ! យើងបានជំនួសអំណាចព្រះសក្កទេវរាជជ្រើសរើសពួកអ្នកទៅកាន់ផែនដីដែនសុវណ្ណភូមិសម្បូរទ្រព្យធន់ឱ្យជួយការពារអនុរក្សមើលថែធ្វើឱ្យព្រះនគរគោកធ្លោកមានច្បាប់ទំលាប់រៀបរយល្អឱ្យមាននិតិរដ្ឋត្រឹមត្រូវមានក្រិត្យក្រំអ្នកធំមានអំណាចចេះអាណិតស្រឡាញ់ការពារយកអាសារអ្នកតូចល្អិតទន់ទាប កូនចៅប្រជានុរាស្ត្រចេះគោរពស្រឡាញ់អ្នកធំមានអំណាចរៀបចំការពារព្រះនគរ។ តើអ្នកទាំងអស់គ្នាបានធ្វើអ្វីឱ្យមានប្រយោជន៍ខ្លះឬទេ នៅទីនោះ ឬគ្រាន់តែទៅស្វែងរកប្រយោជន៍ខ្លួនឯងទៅវិញទេ?”។ គ្មានអ្នកណាម្នាក់ហ៊ានហើបមាត់ឆ្លើយទាល់តែសោះស្ងាត់ឱ្យជ្រាបតែម្តង។ ទេពអគ្គលេខាសម្លឹងរកអ្នកលើកដៃម្នាក់ដើម្បីចោទឆ្លើយតែគ្មានម្នាក់សោះតែម្តងហួសចិត្តលោកទតសម្លឹងទៅរកទេវតាអភិរក្សផែនដីពរៃព្រឹក្សាដែលបានពោលពាក្យត្រគោះបោះបោកព្រហឹនគ្មានចេះកោតក្រែងអំបាញ់មិញនេះ តែឥឡូវបែរជាឱនមុខជ្រុំបបិតមាត់ឆឹងដូចកង្កែប ។ បន្ទាប់មកសម្លឹងទៅរកបុគ្គលទីពីរដែលកំពុងលុតជង្គង់ចង់សុំ មានយោបល់អំបាញ់មិញទេពអគ្គលេខាក៏មានបន្ទូលទៅកាន់

តទៅទំព័រទី ២៨


LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com**

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





## មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម ( ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ )
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

# ដឹងទេថា ផ្លែស្រការនាគ មានប្រយោជន៍អ្វីខ្លះ ដល់សុខភាពមនុស្សយើង?



បេះដូងសរសៃឈាមគ្រាប់របស់ផ្លែស្រការនាគសម្បូរទៅដោយខ្លាញ់អាស៊ីត Polyunsaturated (អូមេហ្គាបី និងអូមេហ្គាប្រាំមួយ)។ ខ្លាញ់ផ្តល់សុខភាពទាំងនេះ នឹងជួយកាត់បន្ថយកម្រិតខ្លាញ់ទរិងលយចរិដសេ និងបន្ថយការប្រឈមនឹងជំងឺបេះដូងសរសៃឈាម។ ផ្លែស្រការនាគ ក៏ផ្ទុកទៅដោយវីតាមីន B3 ដែលអាចបន្ថយកម្រិតកូឡេស្តេរ៉ុលអាក្រក់ និងបង្កើនកូឡេស្តេរ៉ូលល្អផងដែរ។ ក្រៅពីនេះ ផ្លែស្រការនាគត្រូវបានគេទទួលស្គាល់ថា ជួយកាត់បន្ថយការឡើងខ្ពស់នៃសម្ពាធអុកស៊ីតកម្មដែលជាផ្នែកមួយដ៏សំខាន់ក្នុងការបង្កជំងឺបេះដូងសរសៃឈាម។ ជំងឺមហារីកផ្លែស្រការនាគពោរពេញទៅដោយអង់ទីអុកស៊ីដង់ដ៏មានប្រយោជន៍ជាច្រើនដូចជា Phytoalbumins (ដែលមានក្នុងគ្រាប់របស់វា) សម្រាប់ជួយដល់ការបង្ការរ៉ាឌីកាល់សេរីបង្កជំងឺមហារីក។ វាក៏មានវីតាមីនC ខ្ពស់សម្រាប់ទប់ស្កាត់ការលូតលាស់ដុំសាច់មហារីក និងពង្រឹងសុខភាពរបស់អ្នកជំងឺមហារីកផងដែរ (កាត់បន្ថយរោគសញ្ញាដូចជា ការអស់កម្លាំង ចង្អោរ ក្អួត ឈឺចាប់ និងស្រកទម្ងន់)។ ផ្លែនេះ នឹងជួយរាងកាយជំនះនូវជាតិលោហៈពុល និងធ្ងន់ៗដែលជាហេតុនាំឱ្យកើតជាដុំសាច់មហារីកក្នុងខ្លួន។ សម្រួលដល់ការរំលាយអាហារផ្លែស្រការនាគ គឺជាអាហារមានជាតិសរសៃដ៏អស្ចារ្យសម្រាប់ជួយដល់ការសម្របសម្រួលការរំលាយអាហារ និងបង្ការជំងឺទល់លាមក និងរាករូស។ វាអាចជួយឱ្យអ្នកឆ្អែតបានយូរក្រោយពីញ៉ាំរួច ដូច្នេះវាពិតជាល្អណាស់ ចំពោះអ្នកចង់សម្រកទម្ងន់។ ផ្លែឈើមួយនេះ មិនត្រឹមតែធ្វើឱ្យអ្នកសប្បាយចិត្តរយៈពេលយូរទេ តែវានឹងពង្រឹងដល់ការរំលាយអាហារ និងសម្របសម្រួលជាតិស្ករក្នុងឈាម។ ទ្រទ្រង់ប្រព័ន្ធភាពស៊ាំ វីតាមីន និងជាតិរ៉ែដ៏ច្រើន ក្នុងផ្លែស្រការនាគមានដូចជា វីតាមីន C, B1, B2, B3 កាល់ស្យូម ផូស្វ័រ ជាតិដែក ប្រូតេអ៊ីន Niacin និងជាតិសរសៃដែលវាសុទ្ធសឹងតែជួយពង្រឹងដល់មុខងារប្រព័ន្ធភាពស៊ាំទាំងអស់។ ប្រព័ន្ធភាពស៊ាំអ្នកចាប់ផ្តើមនៅក្នុងផ្លូវរំលាយអាហារ ហើយក៏ជួយទ្រទ្រង់ដល់សុខភាពផ្លូវរំលាយអាហារនេះដែរ។ ការទទួលបានវីតាមីន និងជាតិរ៉ែគ្រប់គ្រាន់ក្នុងរបបអាហារនឹងជួយការពារ អ្នកពីការកើតជំងឺ និងឆ្លងជំងឺ។ ជាមួយគ្នានេះដែរ អង់ទីអុកស៊ីដង់ អាចជួយសម្លាប់បាក់តេរី និងវីរុសក្នុងរាងកាយទៀត។ ផ្លែស្រការនាគមានជាតិទឹករហូតដល់៨0 ភាគរយ ដូច្នេះវានឹងជួយច្រោះជាតិពុលពីក្នុងខ្លួនបានយ៉ាងល្អ។ ភ្នែកតើអ្នកចង់ឱ្យភ្នែកមើលឃើញច្បាស់ល្អតាមរយៈការញ៉ាំផ្លែស្រការនាគដែរទេ? ផ្លែឈើមួយនេះ ផ្ទុកទៅដោយ វីតាមីន A ជាទម្រង់ Carotene ដែលជាតម្រូវការសម្រាប់រ៉េទីនរបស់ភ្នែកទាំងចក្ខុវិញ្ញាណពេលយប់ និងពណ៌។ ការខ្វាក់មាន់ និងបញ្ហាភ្នែកផ្សេងៗទៀត ដូចជា Macular Degeneration អាចបណ្តាលមកពីការកង្វះវីតាមីន A ដែរ៕


B&M DISPOSAL 978-569-6062

ក្រុមហ៊ុនដឹកជញ្ជូនសំរាម ប៊ីអឹម



កុងទីន័រដាក់សម្រាម 30 YARD CONTAINER
រហូតដល់ ៤ តោន $549

កុងទីន័រដាក់សម្រាម 20 YARD CONTAINER
រហូតដល់ ៣ តោន $449

កុងទីន័រដាក់សម្រាម 15 YARD CONTAINER
រហូតដល់ ២ តោន $349

*សូមបង់ថែម $100 ក្នុង ១000 ផោនបន្ថែម។ អនុញ្ញាតឱ្យដាក់បន្ថែមលើសទម្ងន់អតិបរមានៅលើកុងទីន័រណាមួយខាងលើបាន។

សូមទាក់ទងឈ្មោះ ប៊ុន ឥឡូវនេះ!
មានផ្តល់សេវាជូនដល់ហាងទំនិញ និងតាមផ្ទះ




BUSINESS – RESIDENTIAL
1687 Middlesex St. Lowell, MA 01851
CAll BUN 978-569-6062



KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us
ផ្សារពាណិជ្ជកម្ម ហ្វីឡាដែលហ្វៀ SomrithSom

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Richard Howe ,Jr. ,Tooch Van
យកព័តមាន Chhan Yon (504) 912 2660

ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng

នាយករដ្ឋបាល Office Manager **978-677-7163**
Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts 100.00 serving 120 Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at or Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

KhmerPost USA is the only Cambodian newspaper that has the highest circulation and is most read in the Cambodian communities in the East Coast of United States. The newspaper prints 32 pages an issue - all in color, premium 35 pound stocks paper. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. Found in 2007 by a respectable Cambodian Journalist, Roger Samkhon Pin, the former President of Cambodian Journalist Association of Cambodia (1994-1997), the Director of Radio Free Asia, Cambodian Services in Washington D.C (1998-2003), and the founder and broadcaster of Cambodian-American news through five Radio Stations around the U.S (2004-2008).

## Publication Frequency

24 times a year.

## General Information

**Circulations:** 15,000 copies per month.

**Distributions:**

- 70+ locations in Lowell, MA (5,000 copies per issues)

**2015 Remaining Prints**

- September 4th & 18th
- October 9th & 23rd
- November 6th & 20th
- December 4th & 18th

* all ad materials are due one due one week prior to the publishing date.




## Advertising Rates

| | 1issue | 3 mo | 6 mo | 12 mo |
|---|---|---|---|---|
| | | 5% off | 7,5% off | 10% off |

**PRICE FOR ADVERTISERS**

| | | | | |
|---|---|---|---|---|
| full | 460.00 | 874.00 | 851.00 | 828.00 |
| 1/2 | 310.00 | 589.00 | 573.50 | 558.00 |
| 1/4 | 165.00 | 313.50 | 305.25 | 297.00 |
| 1/8 | 90.00 | 171.00 | 166.50 | 162.00 |

**Back and Front Page ad spaces are available.**

**Contact: Soben Pin, Managing Partner**

**Office:** 45 Merrimack Street. Suite 218A. Lowell, MA 01852

**Tel:** 978.677.7163. **Cell:** 978. 656.8141. **Fax:** 978.677.7092

Email: sobenpin@khmerpost.us

www.khmerpost.us

Schedules and Rates revision and effective September 2015 – August 2016



# ទៅកម្សាន្តនឹងទេសភាព ទឹកជ្រោះជួរភ្នំជុំជិតព្រឹក្សព្រៃ "ថ្មរូង"







ហាស់ ! ហា់... គយគន់ទឹកជ្រោះឈ្មោះនឹងថ្មដា ស្តាប់សៀងវាគាថ្ងូចថ្ងូរខ្ទរព្រឹក្សព្រៃផ្អើលអស់បក្សីស្រដីខ្សៀវខ្វាររុក្ខាមានភ័ព្វជាប់ជួរអន្លាយលើភ្នំឆើតឆាយស្រស់ស្រាយខៀវខ្ចី, មាត់អូរហូរទឹកសន្ទឹករោងស្បូវមនុស្សម្នារញ៉ូវទៅលេងផ្កាត្រែងហាក់គ្មានចំបែងប្រឡែងគ្នាស្ទិទ្ធទេសភាពល្អពិត ដ្បិតមានប្រុស-ស្រ, ហត្ថាក្បង់ទឹកនឹកដល់កញ្ញាមុជលេងជលសាគាប់នេត្រាក្រៃមិត្តយើងឯណេះចេះចាំចរណៃកុំយូរពេកថ្លៃលែលកអាហារ...។ ទេសភាពបែបនេះ នៅឯណាមាន? គឺនៅរមណីយដ្ឋាន "ថ្មរូង"។

សូមជំរាបថា រមណីយដ្ឋាន "ថ្មរូង" ពិតជាមានទេសភាពស្រស់ត្រកាលដូចពាក្យកាព្យរៀបរាប់លើអញ្ចឹង...ប្រសិនបើយើងធ្វើដំណើរទៅកម្សាន្តទីនោះ នារដូវប្រាំងទេសភាពហាក់ក្រៀមក្រោះបន្តិច ព្រោះតែទឹកហូរតិចតួច ឯដើមឈើធំ-តូចខ្លះស្លោកស្លឹកស្រពាប់ផ្ទាំងថ្មចង្ក្រឹងនៅធ្មឹងស្ងួតទឹកគ្មានសំឡេងរអឹកឈ្ងួឆរអ្វីឡើយ ។ ប្រសិនបើទៅលេងនារដូវវស្សាវិញធានាថា គ្មានទុក្ខទោម្នេញនឹងបរិយាកាសទាំងឡាយនោះឡើយ ដោយសារតែធម្មជាតិស្រស់ខៀវខ្ចីមានភ្នំព្រឹក្សព្រៃព័ទ្ធជុំវិញ ទឹកជ្រោះទឹកអូហូរខ្លាំង១បែកផ្កាត្រែងបង្កសំឡេងឈ្ងួឆរគ្មានដាច់ខ្យល់បក់រ៉ូ១ដើមរុក្ខារេរាំនាំក្លិនពិដោរប៉ះផាត់រាងកាយប្រុស-ស្រីសត្វស្លាបហិចហើរបង្ហើរវាចាពួសូរខ្សៀវខ្វារគួរមេត្រីមនុស្សម្នាអ៊ូអរស្លួចិត្តកម្សាន្តរួចហើយប្រះប្រាណគេងលើអង្រឹង ។ ទីនេះមានលក់ម្ហូបអាហាររាប់សិបមុខ ត្រីដុត មានដុត សម្លម្ជូរ កកូរឆាអាំង ជ្រូក គោ មាន់ ទា ម្ទីម្នា តាមចិត្តជាពិសេសសាច់សត្វព្រៃលែលកកុម្ម៉ង់ឆីមានឱជារស។ មានរោងស្បូវ និងក្បូសមិនខុសចិន្តាជួលញ៉ាំអាហារមិនថ្លៃពេកទេ ទម្រេតខ្លួនប្រាណបានលើអង្រឹងធ្វើហាក់មិនដឹងមិនមានរឿងអ្វី ។ ចង់មុជទឹកលេងប្រឡែងធម្មជាតិក៏បានមានស្រស់កល្យាណនៅក្បែរ១យើង...ស្រង់ទឹករួចរៀបចំខ្លួនសូរិយាអង្រួនជូនដល់សាយ័ណ្ហគ្មាន់ត្រៃវិលវិញ ។

គួរបញ្ជាក់ថា ទៅកាន់រមណីយដ្ឋានថ្មរូងធ្វើដំណើរតាមផ្លូវជាតិលេខ៤រយៈចម្ងាយ១១៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ...ទៅហួសជ្រោះជ្រងពេជ្រនិលបន្តិចឃើញមានដាក់ស្លាកខាងស្តាំដៃ "រមណីយដ្ឋានថ្មរូង" បត់ចូលតាមផ្លូវក្រាលក្រួសក្រហមបត់បែនឡើងចុះតាមជើងភ្នំ ប៉ុន្តែមិនពិបាកទេ ប្រហែល៥គីឡូម៉ែត្រនឹងដល់រមណីយដ្ឋានហើយ ស្ថិតក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុជាប់ព្រំប្រទល់ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ៕




adventuresawait

Greater Merrimack Valley
Convention & Visitors Bureau

For more fun things to see & do
and great places to eat & stay, visit...
www.merrimackvalley.org

សន្តិសុខសង្គមសម្រាប់ពិការភាព
Social Security Disability

Palma Law Offices, P.C.
45 Merrimack Street, Suite 330
Lowell, MA 01852

www.LowellDisabilityLawyer.com - (978)970 2211

# ព័ត៌មានខ្លីៗ សាលារៀនធ្វើក្រចកនឹងកែរសម្ផស្សខ្មែរ

**ដោយ ពិន សំខុន**

ទើបនឹងបើកសម្ពោធជាសាលារៀនខ្មែរលើកដំបូងបង្អស់នៅឡូវែលរដ្ឋម៉ាសាឈូសិត កាលពីថ្ងៃទី៣០កក្កដាកន្លងទៅ "សាលារៀនធ្វើក្រចកនឹងកែរសម្ផស្សខ្មែរ" ដឹកនាំដោយ លោក សេង ហាប់ នឹងភរិយា បានបង្ហាញពីគុណសម្បត្តិថ្មីមួយចំនួន គួរកត់សំគាល់ដែលសហគមន៍ត្រូវការណ៍







សម្រាប់តំបន់ខ្មែរដ៏ធំមួយនេះ នឹងសម្រាប់រដ្ឋផង។

**១-**ងាយស្រួលដល់ការបង្រៀនជាភាសាខ្មែរទាំងគ្រូបង្ហាត់ និងសម្ភារសិក្សាអាចផ្តល់ការងាយស្រួលជាងមុនមានទាំងរថយន្តជូនទៅរៀនដើម្បីឱ្យសិស្សអាចយកអាជ្ញាប័ណ្ណស្រួលជាងពេលមុនៗផង។ នៅសល់តែដំណាក់ការមួយ



ទៀត គឺការប្រឡងជាភាសាខ្មែរដែលសហគមន៍វិជ្ជាជីវកំពង់តែទាមទារនៅឡើយ។

**២-**សាលារៀននេះស្ថិតនៅអាគារសមាគមន៍ខ្មែរកាលពីមុនតាំងពីសមាគមខ្មែរបានចាកចេញប្តូរទីតាំងកាលពីឆ្នាំទៅតំបន់ដែលធ្លាប់តែអ៊ូអរពីមុនបានក្លាយជាសង្ងាត់ជ្រងំធ្វើឱ្យអាជីវករខ្លះបានបិទទ្វារចេញទៅដែរ។ ឥឡូវនេះបាន "សាលារៀនធ្វើក្រចកនឹងកែរសម្ផស្សខ្មែរ" មកឈរជើងនៅក្នុងបរិវេណនឹងនាំសិស្សចាស់ក្មេងប្រមាណ ១០០នាក់ថ្មី មករាល់ថ្ងៃនឹងនាំសេចក្តីសង្ឃឹមថាភាពអ៊ូអរនឹងកើតឡើងមកវិញបាន។

**៣-** លោក សេង ហាប់ បាននិយាយថាចាប់តាំងពីលោកបានផ្សព្វផ្សាយពីសាលារៀននេះ លោកមានសេចក្តីរីករាយដោយមានសិស្សបានមកចុះឈ្មោះច្រើន ហើយដោយសារលោកមានសាលប្រជុំធំទូលាយដែលអាចឱ្យសមាគម ឬ អែកជនអាចមកបើកការប្រជុំរបស់ខ្លួនបាននោះនឹងផ្តល់ភាពចូលចិត្តមកតំបន់ពាណិជ្ជកម្មយើងកាន់តែច្រើនទៀត។

ដូច្នេះខ្មែរផុសនៅសល់តែជូនពរឱ្យដំណើរពាណិជ្ជកម្មបើក "សាលារៀនធ្វើក្រចកនឹងកែរសម្ផស្សខ្មែរ" នៅឡូវែលនេះ បានប្រកបតែជោគជ័យតែប៉ុណ្ណោះ៕







## Khmer Post Subscription form

Khmer Post subscription is $10 for 1month -$30 for 3 month -
$50 for 6 months and $100 for12 months
The price is only for mailing - We send your personal mail via Post office.

យើងទទួលយកតែ "ម៉ានីអ័រឌឺ" តែប៉ុណ្ណោះ -We accept Money order -Check

អាស័យដ្ឋាន Khmer Post address :45 Merrimack St.Suite 218A Lowell, MA 01852

ទូរស័ព្ទ Phone : off.978 677 7163 -Soben's Cell.978-656 8141

- Roger Cell. 978 - 942 1641

<<www.Khmerpostusa.us>> publication is 2 issues per month

### ប័ណ្ណបញ្ជាទិញកាសែត "ខ្មែរផុសស.រ.អា"
### Khmer Post subscription order

ឈ្មោះ - My name.........................................................................

អាស័យដ្ឋាន -Address....................................................................

...........................................................................................

ខ្ញុំចង់ជាវកាសែតខ្មែរផុសស.រ.អា...................ខែ.........តម្លៃជាវ..............ដុល្លារ

I'd like to subscribe Khmer Post USA for ...........
Month(s)-Subscrition price $......................

# ទើបបើកថ្មី ! សាលាខ្មែរបង្រៀនថែសម្ផស្ស និងក្រចកនៅឡូវែល




120 Cross St. Lowell, MA 01854 (Formerly CMAA Building)
www.lowellacademy.net, **978-459-5300**



សាលាខ្មែរដំបូងបង្អស់នៅទីក្រុងឡូវែល ចាប់បើកបង្រៀនជំនាញថែសម្ផស្ស និងធ្វើក្រចកដល់បងប្អូនខ្មែរ ដោយគ្រូខ្មែរជាភាសាខ្មែរ
យើងមានសេវាផ្សេងៗដូចជា •ដឹកជញ្ជូនទៅមក •ជួយរកការងារឱ្យធ្វើ •ណែនាំឱ្យប្រឡងជាប់
ថ្នាក់ផ្តើមថ្ងៃទី ៣១ សីហា ២០១៥ (បីវេន: ថ្ងៃ, យប់, ចុងសប្តាហ៍)

- Class Starts August 31st, 2015 **(Day, Nights, and Weekends)**
- Services : ESL Class • Transportation •Job Placements • Tutoring for Exams

**សូមទាក់ទងដើម្បីចុះឈ្មោះថ្ងៃនេះ !**

**978-459-5300**

ដើម្បីព័ត៌មានបន្ថែមសូមទាក់ទងលោកនាយកគ្រប់គ្រង : សេង ហាប់រឿន តាមលេខទូរស័ព្ទ : (978) 888-8099